# កុលាបប៉ៃលិន

(ប្រភពឯកសារ៖ http://www.khmerreader.com)

## វគ្គទី៤
## ចោរកម្មកើតឡើងនាកណ្តាលព្រៃស្ងាត់

លុះព្រះអាទិត្យជិតអស្តង្គតទៅ នៅតែមានរស្មីព្រឿងៗឆ្លុះនៅចុងព្រឹក្សា បន្តិចក៏ដល់ពេលព្រលប់យប់ងងឹត ថៅចិត្រក៏បង្កាត់ភ្លើងឲ្យឆេះដង្គោល មានពន្លឺភ្លឺប្រាលរន្ទាល ដើម្បីឲ្យមានពន្លឺផងដើម្បីការពារសត្វសាហាវយង់ឃ្នងផង។ ឯនាងនារីអង្គុយនិយាយសន្ទនាចប្រាប់នឹងលោកបាឡាត់ លើកំណាត់ឈើមួយដុំ មិនចេះអស់មិនចេះហើយ។ ចំណែកខាងលោកហ្លួងរតនសម្បត្តិ ដោយសេចក្តីនឿយហត់អស់កម្លាំងពេក ក្រោយពេលដែលលោកពិសាក្រយាហើយ ក៏ប្រះសម្រាន្តលក់ក្នុងរថយន្តនោះទៅ។

មុខគួរឲ្យអនិច្ចាដល់ថៅចិត្រ អុជបារីជក់អង្គុយសំកុកមើលពន្លឺភ្លើងភ្លឺះៗតែម្នាក់ឯង ដែលលើភ្លើងភ្នក់កំពុងឆេះប្រាលរន្ទាល ឯគំនិតចេះតែគិតផ្សេងៗ អណ្តែតអណ្តូងទៅតាមអារម្មណ៍របស់ចិត្ត យូរៗដកដង្ហើមធំម្តង ប្រហែលជាចង់ជម្រុះទុក្ខធំដែលកប់នៅក្នុងទ្រូងឲ្យជ្រុះធ្លាក់ទៅខ្លះ។ ការធ្វើយ៉ាងនេះជាកិរិយារបស់មនុស្សដែលមានទុក្ខធ្ងន់ក្នុងទ្រូង តែទុក្ខសោកក្រហល់ក្រហាយរបស់បុរសកម្លោះៗដូចជាថៅចិត្រ នេះគង់មិនមានអ្វីក្រៅពីសេចក្តីស្នេហាប្រតិព័ទ្ធចំពោះរូបស្ត្រីក្រមុំណាមួយប៉ុណ្ណោះ ប៉ុន្តែសេចក្តីស្រឡាញ់របស់ថៅចិត្រ នេះខុសខ្វង់គ្នាឆ្ងាយណាស់ ហាក់ដូចឈោងដៃចាប់បេះផ្កាយលើមេឃ ឥឡូវនេះថៅចិត្រទទួលលន់តួថាខ្លួនចាប់ចិត្តស្នេហាលើរូបនាងនារី ដែលជាថៅហ្វាយក្រមុំរបស់ខ្លួន ទុកជាមិនសមសក្តិគ្នាយ៉ាងណាក៏ដោយ ក៏ថៅចិត្រយល់ថាសេចក្តីស្រឡាញ់ស្នេហារបស់បុរសស្ត្រីក្នុងលោកនេះ មិនមានកំរិតកំណត់ព្រំប្រទល់ដូចម្តេចឡើយ ដូច្នេះហើយបានជាថៅចិត្រចង់ឈោងបេះផ្កាកុលាបបប៉ៃលិននេះ តែមកនឹកគិតថា ខ្លួនដៃខ្លីមិនគួរគប្បីប្រវាឱបភ្នំសោះ នឹងនាំឱ្យកើតទុក្ខទោមនុស្សក្រៀមក្រំ ទៅជាស្រឡាញ់បង់ចិត្តឥតប្រយោជន៍ នឹកមកដល់ត្រឹមនេះថៅចិត្រដកដង្ហើមធំម្តងៗ បារីមួយក៏ឆេះអស់ទៅ ហូតបារីមួយទៀតមកជក់ជិតអស់ពាក់កណ្តាល ឯគំនិតចេះតែគិតទៅៗយ៉ាងលន្លង់លន្លោចតែម្នាក់ឯង ចំណែកខាងនាងនារី និយាយសន្ទនាជាមួយនឹងបាឡាត់ស្រុកនោះហាក់ដូចជាត្រូវចិត្តគំនិតគ្នាណាស់។

ថៅចិត្របានឃើញកិរិយាដូច្នេះ កើតគំនិតឥច្ឆាឈ្នានីសលោកបាឡាត់យ៉ាងលើសលន់ មើលទៅគេទាំងពីរនាក់ស្រុះស្រួលគ្នាល្អណាស់ ដូចជាគេវេញឆ្លុងមួយ ប្រហែលជាគេស្រឡាញ់គ្នារួចទៅហើយទេដឹង! មែនហើយ! បាឡាត់នេះគាត់នៅលីវ ថែមទាំងមានទ្រព្យធនគ្រាន់បើផង ហើយរូបឆោម

សោតទៀតក៏មិនជាអាក្រក់ប៉ុន្មាន នាងនារីគង់ប្រថុយស្រឡាញ់គេរួចទៅហើយ ចុះចំណែកខាងអញ អញមានភាពដូចម្តេចទៅ? នាងនារីមានសភាពដូចម្តេចនៅខ្ពង់ខ្ពស់ទាបជាងគ្នាឆ្ងាយណាស់ បើទុកជានាងនារីនឹកស្រឡាញ់អញដែរ ក៏គង់មិនហ៊ានប្រថុយទេ ក្រែងខូចកេរ្តិ៍ឈ្មោះវង្សត្រកូលរបស់នាង ព្រោះអញមានឋានៈត្រឹមកម្មករ ហើយជាកម្មកររបស់នាងទៀតផង គឺអាត្មាអញតូចទាបទាំងបុណ្យសក្តិ ទាំងទ្រព្យធន ទាំងរបររកស៊ី ដូច្នេះអាត្មាអញមិនគួរជាប់ចិត្តស្រឡាញ់នាងទេ ដូចមានពាក្យបុរាណចងក្រងទុកថា "ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងប្រវាឱបភ្នំ ឬ ដៃតូចខ្លួនទាប ចង់ឈោងចាប់ផ្កាយ" ចៅចិត្រគិតមកដល់ត្រង់ណេះ ស្រាប់តែកើតគំនិតមួយជជែក នឹងគំនិតមុនថា ធម្មតាសេចក្តីស្នេហាស្រឡាញ់នេះមិនមានកំរិតជាន់ថ្នាក់អ្វីឡើយ ប្រុសស្រីគ្រប់រូបគេអាចស្រឡាញ់គ្នាបានតាមចិត្តស្ម័គ្ររបស់ខ្លួន សេចក្តីសំខាន់បំផុតស្រេចទៅលើម្ចាស់ខ្លួនខាងស្រីទេតើ! លុះចៅចិត្រគិតដូច្នេះហើយក៏ដកដង្ហើមវែងម្តង ដើម្បីឲ្យធូរទ្រូងបន្តិច។

សូរស្បែកជើងតន្លើនចូលមកជិត ចៅចិត្រក៏ក្រឡេកមើលឃើញនាងនារីកាន់កាំភ្លើងខ្លីមួយនៅក្នុងដៃមកផង ហើយសួរថា "មិនទាន់ងងុយដេកទេឬ ចិត្រ?"
ចៅចិត្រញញឹមហើយថា "ខ្ញុំបាទមិនទាន់ងងុយទេ យុន! នៅវេលានេះមិនទាន់ជាយប់ជ្រៅប៉ុន្មានទេ តែនៅកណ្តាលព្រៃ មើលទៅឃើញហាក់ដូចជាយប់អាធ្រាតណាស់ទៅហើយ!"
នារីៈ "ស្រួលហើយចិត្រ! បើមិនទាន់ងងុយនៅចាំយាមទៅសិនចុះហ៎! យកកាំភ្លើងនេះទុកបង្ការខ្លួន បើងងុយដេកវេលាណា ទៅដាស់លោកបាឡាត់ ឲ្យមកចាំយាមជំនួសវិញ"។
ចៅចិត្រទទួលយកកាំភ្លើងមក ហើយក៏សួរទៅនាងវិញថា "ចុះយុន នឹងអញ្ជើញទៅសម្រាន្តឥឡូវនេះឬ?"។
នារីញាក់មុខហើយថា "ខ្ញុំគិតដេកពីព្រលប់បន្តិច ត្បិតអស់កម្លាំងតាំងពីថ្ងៃមកហើយ"។
ចិត្រៈ "យុននឹកខ្លាចទេ ការដែលមកស្នាក់ក្នុងព្រៃស្ងាត់ដូច្នេះ?"។
នាងញាក់ស្មាម្ខាងថា "ខ្ញុំក៏នឹកខ្លាចខ្លះដែរ តែមិនសូវជាច្រើនប៉ុន្មានទេ"។
ចិត្រៈ "បើដូច្នេះ សូមយុនមេត្តានៅកំដរខ្ញុំបានបន្តិចសិនចុះ"។
នារីៈ "អ្នកឯងខ្លាចណាស់ឬ ចិត្រ?"
ចិត្រៈ "សូមទោស ខ្ញុំបាទមិនជាខ្លាចណាស់ណាទេ ប៉ុន្តែខ្លាចក្រែងងក់ជ្រុល ដេកលក់ទៅ នាំឲ្យខូចការធំ!"
នាងនារីនៅតែស្ងៀម ទើបចៅចិត្ររកឧបាយផ្តើមនិយាយឡើងមុនថា "ចុះយុន នឹកទៅផ្ទះដែរឬទេ?"
នារីៈ "ខ្ញុំនឹកដល់ផ្ទះច្រើន ចិត្រ! ព្រោះមិនមានចាស់ទុំនៅចាំផ្ទះសោះឡើយ"។
ចិត្រៈ "ព្រឹកស្អែកនេះ គង់តែបានទៅដល់ផ្ទះទាំងអស់គ្នា" ចៅចិត្រនិយាយបន្តិច ស្ទើរតែមិនឮហើយថា "បើយប់នេះមិនមានរថឬរទេះមកតាមផ្លូវនេះទេ ខ្ញុំបាទនឹងក្រោកពីយប់ចេញដើរទៅ

ប្រហែលជាថ្ងៃរសៀល គង់វិលមកទទួលឃុនត្រឡប់ទៅដល់ផ្ទះទាំងអស់គ្នាមិនខាន”។
នារីៈ “ដើរទៅរួចឬ ចិត្រ? ត្បិតផ្លូវពីនេះទៅផ្ទះយើងវាឆ្ងាយក្រៃលដែរ មិនមែនជិតទេ”។
ចិត្រៈ “ទុកជារួចមិនរួចក៏ខ្ញុំបាទត្រូវតែទៅ បើខ្ញុំបាទមិនទៅទេ មុខតែនាំគ្នាដេកផ្លូវនៅទីព្រៃនេះជាច្រើនយប់ទៅទៀតមិនខានទេ ឱ! នុះហ្ន៎ ឃុន ព្រះចន្ទ្រនិងផ្កាយតូចៗនៅខាងត្បូងនោះល្អមើលណាស់ ឃុនគាប់ចិត្តនឹងធម្មជាតិនោះដែរឬទេ? ឯខ្ញុំបាទចូលចិត្តណាស់!”
នាងនារីសំឡឹងមើលទៅតាមដៃដែលចៅចិត្រចង្អុលប្រាប់ ព្រមទាំងចិត្តគំនិតក៏រីករាយទៅជាមួយផង ឥឡូវនេះនាងបាត់ស្អប់ខ្ពើមចិត្រ ហើយបែរជាមានសេចក្ដីពេញចិត្តថែមទៀតផង។ ចៅចិត្រជាប្រុសកម្លោះដំបូងដែលធ្វើឲ្យនាងមានចិត្តគំនិតយ៉ាងចំលែកប្លែកជាងពីមុនមក ឯកម្លាំងរបឹងរឹងរូសរបស់នាងក៏ថយខ្សោយចុះទៅជាលំដាប់ ឥឡូវចិត្តនាងបែរជាទន់ភ្លន់ល្វន់ល្វៃដូចជាក្រមួនត្រូវកំដៅថ្ងៃ។
ចៅចិត្រសំឡឹងមើលដួងចន្ទ្រដោយអាការស្ងាត់ស្ងៀម តែខាងក្នុងចិត្តដូចជាអណ្ដែតអណ្ដូងយ៉ាងចំឡែក ភ្នែកក៏មើលធម្មជាតិដ៏ល្អល្អះនៅខាងមុខ ហាក់ដូចជាមិនដឹងខ្លួនថានាងនារីដែលជាកុលាបក្រពុំព្រហ្មចារីនៅក្បែរខ្លួនឡើយ។
កាលនាងឃើញចៅចិត្រនៅសម្ងំស្ងៀមដូច្នេះ ហើយឮសូរដកដង្ហើមវែងម្ដងៗ ទើបសួរខ្សឹបៗថា “កើតទុក្ខអី ចិត្រ?”
ចិត្រៈ “បាទ ខ្ញុំបាទកើតសេចក្ដីអផ្សុកយ៉ាងចំឡែក!”
នាងនារីញញឹមបន្តិចៗ ហើយសួរថា “ម៉េច អផ្សុកនឹកក្រមុំស្រុកសង្កែឬ?”
ចៅចិត្រសើចយ៉ាងសោះកក្រោះហើយសួរថា “ស្រុកសង្កែឬ ឃុន? ខ្ញុំបាទឥតនឹកនាបន្តិចឡើយ តាមដោយពិតនោះវាជាស្រុកស្រណុកសប្បាយសម្រាប់អ្នកមានធនធាន ឯអ្នកទីទ័លក្រដូចរូបខ្ញុំបាទនេះ មិនបានអ្វីនាំឲ្យជាប់ចិត្តបន្តិចឡើយ”។
នារីសើចហើយសួរទៀតថា “ចុះស្រុកបប៉ៃលិននេះ តាំងពីចិត្រមកនៅ តើនាំឲ្យបានសប្បាយចិត្តជាងនៅស្រុកសង្កែឬ?”
ចិត្រៈ “បាទ បប៉ៃលិនឲ្យសេចក្ដីសុខដល់ខ្ញុំបាទច្រើនណាស់ ដល់ទៅនឹកចង់ធ្វើផ្នឹងនៅនឹងស្រុកនេះតែម្ដង!”
នារីៈ “ចុះខណៈនេះ អ្នកនឹកនរណា បានជាមានទឹកមុខក្រៀមក្រំខ្លាំងម្ល៉េះ?”
កាលនាងនារីផ្លាស់សព្ទថ្មីពី “ចិត្រ” មកជា “អ្នក” ដូច្នេះ ធ្វើឲ្យចៅចិត្រមើលមុខនាងនារី សំឡឹងទាល់តែនាងនារីងាកមុខចេញ បែរមើលស្មៅនៅចិញ្ចើមថ្នល់។
ចិត្រៈ “ឃុន ប្រើពាក្យថា “អ្នក” ជំនួស “ចិត្រ” នោះ ដូចជាខ្ពស់ពេកសំរាប់ខ្ញុំបាទ សូមឲ្យឃុនមានប្រសាសន៍ដូចមុនល្អជាង!”
នារីស្ងៀមមួយស្របក់ ហើយពោលថា “ខ្ញុំគាប់ចិត្តប្រើពាក្យនេះជាង វាមិនខ្ពស់ហួសទេ ជាពាក្យសុភាពគួរសមហើយ!”។

ថៅចិត្រនៅស្ងៀម ទើបនាងនិយាយទៅទៀតថា "អ្នកមិនទាន់ឆ្លើយពាក្យសួររបស់ខ្ញុំនៅឡើយ ខ្ញុំសួរថា នៅបប៉ៃលិនឲ្យសេចក្តីសុខអ្វីដល់អ្នកខ្លះ ?"

ចិត្រ៖ "ឲ្យច្រើនយ៉ាងណាស់ យុន!"

នារី៖ "អើ! អ្វីខ្លះ ?"

ចិត្រ៖ "ឲ្យមានរបរធ្វើការរកស៊ីដោយសុចរិត ធម្មជាតិដ៏ស្រស់បស់គួរជាទីត្រេកត្រអាល ខ្យល់អាកាសក៏ល្អ សេចក្តីសុខ ឥស្សរភាព និង ..."

នារី៖ "និងអ្វីទៀត ?" (នាងឈ្លេចសួរ)។

ថៅចិត្រសំលឹងមើលមុខនាងដោយសេចក្តីប៉ុនប៉ងអ្វីមួយនៅខាងក្នុងចិត្ត ហើយនិយាយខ្សាវៗ ស្ទើរជាខ្សឹបថា "នឹងសេចក្តីស្នេហា!"

នារី៖ "សេចក្តីស្នេហា!" នាងផ្ទួនពាក្យឡើង ទឹកមុខក្រហមព្រឿងៗ។

ចិត្រ៖ "ទានប្រោស សេចក្តីស្នេហារបស់ខ្ញុំបាទជាសេចក្តីស្នេហាដ៏បរិសុទ្ធពិតប្រាកដណាស់ ហើយជាស្នេហាដែលផ្តើមកើតឡើងជាដំបូងបង្អស់ក្នុងជីវិតរបស់ខ្ញុំបាទនេះផង"។

នាងនារីហាក់ដូចជាដឹងដល់ដួងចិត្តរបស់ថៅចិត្រ ដែរតែធ្វើជាឥតដឹង ឥតយល់អ្វីដល់តិចឡើយ ហើយសួរតទៅទៀតថា "អ្នកឯងស្រឡាញ់អ្នកណា ?"

ចិត្រ៖ "ខ្ញុំស្រឡាញ់ស្រីម្នាក់"

នារី៖ "ខ្ញុំដឹងហើយថាស្រឡាញ់ស្រី តែស្រីនោះនៅឯណា ? ឈ្មោះអ្វី ? ឬមួយនាងម៉ាយ៉ុង កូនក្រមុំតាម៉ង់យ៉ុក មេអណ្តូងត្បូងមួយនៅខាងជើងផ្ទះយើងឬ ?" នាងថាហើយសើចយ៉ាងស្រួល។

ថៅចិត្រគ្រវីក្បាលជំនួសពាក្យតប។

នារី៖ "អើ យ៉ាងចឹងនាងណាអះ ឬមួយនាងព្រហ្ម កូនក្រមុំតាសុន ?"

ថៅចិត្រក៏គ្រវីក្បាលទៀត ជាសេចក្តីបដិសេធថាមិនមែនទាំងអស់។

នាងនារីញញឹមស្រួលដោយអស់សំណើចនឹងថៅចិត្រ ហើយថា "អេះ ប្រហែលជាអាមួយ កូនចឹកសេង លក់ទឹកកកនៅមុខផ្ទះយើងទេដឹង ?"

ថៅចិត្រគ្រវីក្បាលទៀតហើយ "ខុសទាំងអស់ ស្ត្រីដែលខ្ញុំបាទស្រឡាញ់នោះ មានថ្នាក់ជាន់ដោយឡែកពីគ្នានឹងខ្ញុំបាទ នាងមានឋានៈខ្ពស់ខ្ពង់ជាងខ្ញុំបាទច្រើន ទាំងកិត្តិយស ទាំងទ្រព្យសម្បត្តិ វង្សត្រកូលខ្ពស់ ទាល់តែខ្ញុំបាទឈោងតោងទៅមិនដល់ឡើយ ហេតុនេះហើយបានជាខ្ញុំជំរាបថា សេចក្តីស្នេហារបស់ខ្ញុំបាទនេះ ប្រហែលនឹងការយល់សប្តិនឹងត្រឡប់ទៅជារឿងពិតមិនបានឡើយ"។

កាលបើនាងបានឮសំដីថៅចិត្រនិយាយយ៉ាងក្រៀមក្រំខ្លោចផ្សា ដោយអស់សង្ឃឹមក្នុងចិត្តដូច្នេះហើយ បេះដូងនាងក៏ណែនតានតឹងក្នុងឱរាជាខ្លាំង នាងចង់តែសុំលន់តួប្រាប់ដោយត្រង់ៗថា នាងក៏ស្រឡាញ់ថៅចិត្រជាខ្លាំងដែរ តែអនិច្ចាខ្លួនជាស្ត្រីនិយាយសំដីដូច្នេះសមគួរហើយឬ ? ឯសំដីថៅចិត្រគ្រប់ម៉ាត់នាងស្តាប់បានទាំងអស់ ឥតមានខ្វះកន្លះត្រង់ណាមួយម៉ាត់ ត្បិតខ្លួននាងមានវ័យចំរើនធំហើយ មិនមែនកូនក្មេងតូចទើបនឹងលែងបៅដោះកាលណា ប៉ុន្តែនេះវារហ័សពេកណាស់។

ឱ! ចិត្រអើយ! នឹងបញ្ចេញប្រាប់រួសរាន់ដូចម្ដេចបាន ក្នុងថ្ងៃណាមួយ ចិត្រគង់បានដឹងថា នារីឥតស្អប់ខ្ពើមទេ ថែមទាំងមានចិត្តស្នេហាស្រឡាញ់ទៀតផង មិនឥឡូវឥឡាទេ ជាវេលាយូរថ្ងៃខែមកហើយ។

ឯភ្លើងភ្នក់ក៏រលត់សូន្យឈឹងទៅ សូរសព្ទវ៉ៃយំឮលាន់រំពងព្រៃ មាន់ក៏មមើលរងាវក្នុងរាត្រីស្ងាត់ ទឹកសន្សើមក៏ជ្រុះស្រក់ចុះពីស្លឹកឈើមិនដាច់សូរ ហើយមើលឃើញសក្បុសនៅចុងស្មៅ ខ្យល់ត្រជាក់បក់មកត្រូវរាងកាយ នាំឲ្យរងាខ្លាំងឡើង ភ្នំខ្ពស់ត្រដែតនៅខាងមុខ ត្រង់កណ្ដាលពន្លឺដួងចន្ទ្រានោះហាក់ដូចអសុរកាយចាំឃ្លាំរក្សាព្រៃព្រឹក្សាដ៏ស្ងាត់ច្រៀបនោះ។ ថៅចិត្រស្ទុះក្រោកឡើងលត់ខ្លួនប្រាណឲ្យបាត់រោយស្រពន់ ដែលទ្រាំអង្គុយនិយាយមកជាវេលាយូរ ហើយដកដង្ហើមធំ។

ចិត្រ៖ "យប់ជ្រៅណាស់ហើយ អញ្ជើញយុនទៅសម្រាន្តឯរថយន្តជាមួយលោកឪពុកចុះ ខ្ញុំបាទនៅចាំយាម សូមកុំព្រួយឲ្យសោះ!"

នារី៖ "ចុះអ្នកឯងមិនទាន់ងងុយដេកទេឬ?" នាងក្រោកដើរទៅ ហើយងាកមកញញឹមបន្តិច។

ចិត្រ៖ "ខ្ញុំបាទមិនទាន់ងងុយទេ អញ្ជើញយុនទៅសម្រាន្តចុះ កុំបីមានសេចក្ដីព្រួយខ្លាចឲ្យសោះ អ្នកដែលចូលមកធ្វើអន្តរាយដល់យុនបាននោះ លុះត្រាតែខ្ញុំបាទស្លាប់ទៅជាខ្មោចមុនស្រេចហើយ ខណៈនោះខ្ញុំបាទនឹងយកជីវិតរក្សាការពារអន្តរាយគ្រប់ទិស សូមឲ្យយុនសម្រាន្តជាសុខចុះ"។

នាងនារីងាកបែរទៅរកថៅចិត្រម្ដងទៀត ព្រោះបានឮសំលេងស្រែកហៅដោយសំលេងភិតភ័យតក្កមា។

"ឃើញទេ យុន! នុះហ្ន៎! ពន្លឺភ្លើងចម្លែកណាស់!"

នាងនារីសំឡឹងមើលតាមដៃដែលគេចង្អុលប្រាប់ ក៏បានឃើញពន្លឺភ្លើងដូច្នេះមែន នៅចម្ងាយជាង១គីឡូម៉ែត្រ នាងខំសង្កេតមើលទៅកាន់តែឃើញពន្លឺគប់ភ្លើងច្រើនឡើងៗ ហើយដើរសំដៅចូលមកកាន់តែជិតឡើងៗ នាងមានសេចក្ដីភ័យខ្លាចយ៉ាងខ្លាំង ញាប់ញ័រអស់សារពាង្គកាយ ព្រោះមិនដឹងជាមានហេតុល្អឬអាក្រក់ដូចម្ដេច នាងស្ទុះទៅចាប់ដៃចិត្រជាប់ដោយមិនដឹងខ្លួនប្រាណបន្តិចសោះ។

ថៅចិត្រច្រកគ្រាប់កាំភ្លើងរួចស្រេច ប្រាប់នាងនារីឲ្យទៅដាស់លោកហ្លួងនិងលោកបាឡាត់ឯរថយន្តមួយស្របក់ជនទាំង៣នាក់ត្រឡប់មកវិញព្រមគ្នា។

លោកហ្លួងសួរយ៉ាងសស្លើកស្លក់ថា "កើតអីហ៎ា! ថៅចិត្ត?" ថៅចិត្រចង្អុលទៅពន្លឺដែលកំពុងតែចូលជិតមកៗ ហើយថា "ទានប្រោស! សូមពិនិត្យមើលគប់ភ្លើងនុះ មិនទាន់ដឹងជាអ្វីទេ!"

"ប្រហែលជាពួកចោរទេដឹង?" លោកបាឡាត់និយាយឡើងមុនគេ។

"ប្រហែលជាពួកចោរមែន!" ថៅចិត្រថាផ្ទួន។ កាលថៅចិត្រនិយាយដូច្នោះហើយ ហ្លួងរតនសម្បត្តិ និងលោកបាឡាត់ក៏នាំគ្នារត់ទៅរថយន្ត រកបានដែករវៃរថយន្តមួយម្នាក់សម្រាប់ប្រើជាអាវុធបង្ការខ្លួន។

ឯងនាងនារីញ័រខ្លួនចំប្រប់ដូចកូនសត្វ ឈរនៅក្បែរថៅចិត្រ ថៅចិត្រចាប់ដៃនាងជាប់ ហើយប្រាប់ថា

"យុន កុំតក់ស្លុតឲ្យសោះ ធ្វើចិត្តឲ្យក្លាហានឡើង យុនភ្លេចពាក្យដែលខ្ញុំបាទបានសន្យានឹងយុនហើយឬ?"
នាងមិនតបដូចម្តេចឡើយ គ្រាន់តែចាប់ដៃជាប់ដោយភ័យស្លន់ ចៅចិត្រប្រុងខ្លួនយ៉ាងអង់អាច រង់ចាំពេលវេលាដែលនឹងមានមកដល់ឥឡូវនេះ ជាពេលវេលាដែលមិនទាន់ដឹងជាមានហេតុភេទដូចម្តេចកើតឡើងនៅខណៈនោះទេ។

នៅទីបំផុតស្រាប់តែឮសំលេងស្រែកហ៊ោកងរំពងនាកណ្តាលព្រៃស្ងាត់ នាំឲ្យដឹងថាពួកចោរនោះមានចំនួនច្រើននាក់ ហើយឮសូរកាំភ្លើងច្រើនណាត់បាញ់តម្រង់មក មានគ្រាប់កាំភ្លើងខ្លះធ្លាក់នៅខាងមុខចៅចិត្រក៏មាន។
អ្នកទាំងពីរ គឺលោកហ្លួងនិងលោកបាឡាត់ថយក្រោយ ទៅយករថយន្តជាគ្រឿងកំបាំងអន្តរាយ ហ្លួងរតនសម្បត្តិទុកជាចាស់ហើយក៏ពិតមែន តែនៅមានស្មារតីរហ័សរវាងវៃណាស់សមជាបុរស។ ឯលោកបាឡាត់សស្លើតសស្លក់ ខំលូនចូលទៅនៅខាងក្រោមរថយន្ត ឯងនាងនារីមិនព្រមឃ្លាតឆ្ងាយពីចៅចិត្រឡើយ នៅតែចាប់ដៃជាប់ស្អិត ក្នុងខណៈនោះចៅចិត្រអែបបំបាំងខ្លួននឹងដើមស្រឡៅធំៗ។

សូរសំលេងហ៊ោគឹកកងរំពងនោះកាន់តែជិតមកៗ ចៅចិត្រខាំធ្មេញយ៉ាងណែន ផ្គងកាំភ្លើងប្រុងស្មារតីយ៉ាងអង់អាច ត្រៀមខ្លួនចាំតទល់នឹងសត្រូវដើម្បីការពារស្រីជាទីស្រឡាញ់ពេញចិត្តរបស់ខ្លួន ជីវិតខ្លួននិងអ្នកទាំងអស់គ្នា។
ពួកមហាចោរក៏បាញ់កាំភ្លើងគ្រាប់ប្រាយមកបាចសាចដូចជាគ្រាប់ភ្លៀងតែ ឥតត្រូវរាងកាយនរណាមួយឡើយ ព្រោះទីនោះជាទីងងឹតឈ្លុបចាក់ភ្នែកពុំយល់ ចំណែកខាងពួកចោរមានគប់ភ្លើងភ្លឺសន្ធោសន្ធៅពេញទាំងព្រៃ ដូច្នេះបានជាគ្រាប់កាំភ្លើងដែលចៅចិត្របាញ់ទៅគ្មានខុសមួយគ្រាប់ ចោរខ្លះបាក់ដៃ ខ្លះបាក់ជើង ខ្លះដួលចង្ក្រាងទៅក៏មាន តែគ្រាប់កាំភ្លើងមានតិចពេក បានជាមិនអាចនឹងប្រហារចោរដែលមានចំនួនច្រើននោះអោយមានជ័យជំនះបានឡើយ។
ចៅចិត្រខំតស៊ូយ៉ាងក្លាហានដើម្បីការពារជីវិតខ្លួននិងជីវិតស្ត្រីសំឡាញ់របស់ខ្លួនដោយអង់អាចឥតខ្លាចស្លាប់បន្តិចឡើយ។
ហេតុភេទដែលមុខគួរឲ្យស្ញប់ស្ញែងនេះ នៅមិនទាន់ដឹងជាខាងណាចាញ់ឬឈ្នះឡើយ ពួកចោរទុកជាត្រូវគ្រាប់ដួលទៅជាច្រើននាក់ហើយក៏ដោយ ក៏ឥតរួញថយក្រោយ ហើយមានតែរុកចូលមកថែមកាន់តែច្រើនឡើងៗ ហើយចូលមកជិតទៅៗ ឥតឈប់ឈរ កាន់តែជិតខ្លួនគ្រប់ៗខណៈ។

ចៅចិត្របែរមកអោបនារីជាប់ ហើយនិយាយខ្សឹបប្រាប់នឹងត្រចៀកថា "គ្រាប់កាំភ្លើងនៅសល់តែមួយគ្រាប់ទេ យុននារី! ខ្ញុំបាទសូមលន់តួជំរាបយុនដោយស្មោះត្រង់ថា ខ្ញុំបាទមានចិត្តស្រឡាញ់យុនក្រៃលែងជាងជីវិតរបស់ខ្ញុំបាទទៅទៀត ត្បិតក្នុងខណៈនេះ ពេលវេលាកាន់តែជិតដល់ទីបំផុតហើយ

ខ្ញុំបាទនឹងទ្រាំលាក់យូរទៅទៀតពុំបាន ព្រោះអវសាននៃជីវិតខ្ញុំបាទកាន់តែចូលទៅជិតដល់ស្រុកខ្មោច ហើយ យុននារី ខ្ញុំបាទត្រូវតែស្លាប់ក្នុងគ្រានេះហើយ! មើលចុះពួកវាគ្នាច្រើនណាស់ វាគង់មិនទុកជីវិតខ្ញុំបាទឲ្យរស់នៅទេ ឯគ្រាប់កាំភ្លើងមួយគ្រាប់នេះ ខ្ញុំបាទនឹងចេញតទល់ការពារយុន ដោយយកជីវិតខ្ញុំបាទចេញរងជំនួស សូមឲ្យយុនរត់ទៅពួនចុះ ខ្ញុំបាទនៅតស៊ូនឹងពួកវា"។

ចៅចិត្រសំដែងកិរិយាសោកស្ដាយស្រណោះអាឡោះអាល័យយ៉ាងពន្លឹក ហើយសួរបញ្ជាក់ថែមទៀតថា "ស្រឡាញ់បងទេ នារី"

នារី៖ "ចា៎! ស្រឡាញ់ ចិត្រ ខ្ញុំស្រឡាញ់ចិត្ររបស់នារីតែមួយនេះជាបណ្ដូលចិត្តរបស់នារី!" នាងនិយាយទាំងទឹកមុខដោយក្ដីរីករាយ ដោយក្ដីភិតភ័យលាយឡំគ្នាស្ទើរ និយាយមិនចេញ។

ចិត្រ៖ "ស្រឡាញ់ខ្ញុំ! ឱបណ្ដូលជីវិតរបស់បង! តែប៉ុណ្ណេះបងធ្មេចភ្នែកស្លាប់ជាសុខហើយ ប្អូនមាសព្រលឹង!"

នៅវេលាដែលនារីងាកទៅពួននឹងគល់ស្រឡៅវិញ ចៅចិត្រក៏តម្រង់កាំភ្លើងបាញ់ទល់នឹងពួកចោរ ស្រាប់តែឮសូរស្រែកយ៉ូយឡើង ដោយឈឺចាប់យ៉ាងខ្លាំង ចៅចិត្រយកដៃឱបដើមទ្រូង នារីឃើញដូច្នេះក៏ញ័ររន្ធត់ទាំងខ្លួនប្រាណ។

ចៅចិត្រស្រែកប្រាប់នារីថា "ខ្ញុំត្រូវគ្រាប់របស់ចោរហើយ យុននារី!" គេស្រែកថ្ងូរតែក្នុងបំពង់ក ហើយមានឈាមហូរចេញពីខ្លួនក្រហមច្រាល ហើយប្រាប់ថា "យុននារី កុំនៅ! រត់! រត់ទៅជាប្រញាប់ ទើបផុតអំពីកណ្ដាប់ដៃពួកចោរ!" នាងទើបតែងើបពីគល់ស្រឡៅ ស្រាប់តែឮសូរប៉ុង! ប៉ុង! ជាច្រើនណាត់បាញ់មកទៀត ទើបនាងមុជក្បាលពួននៅគល់ស្រឡៅទៅវិញ ឯចៅចិត្រក៏ដួលសន្លប់លើផ្ទៃផែនដីនៅត្រង់នោះឯង"។

# វគ្គទី៥
## សេចក្ដីស្នេហាកើតក្រោយឧប្បត្តិហេតុ

មានពន្លឺឆ្លុះចាំងមកស្រទន់ៗនៃអរុណដែលទើបរះឡើងពីទិសបូព៌ានោះ មានពណ៌ភ្លឺប្រាលផ្លៅ ជាសម្បុរមាសយ៉ាងល្អ ហើយចាំងចូលតាមចន្លោះបង្អួចនិងចន្លោះទ្វារ វេលានោះមានសត្វចាបតូចៗពីរបីហើរធ្វៀលធ្វាត់ទទះស្លាបលេងយ៉ាងក្សេមក្សាន្តឥតមានព្រួយ អំពល់រវល់នឹងសេចក្ដីទុក្ខសោករបស់អ្នកឯណាឡើយ វាហើរកំសាន្តចិត្តនៅកណ្ដាលខ្យល់ដែលកំពុងបក់មករំភើយៗ ក្នុងពេលព្រឹកព្រហាម ហើយស្រែកហ៊ោកញ្ជៀវទៅតាមភាសាសត្វ។
ឯចៅចិត្រប្រែខ្លួនភ្ញាក់ស្មារតីឡើង ហើយស្រែកថ្ងូរដោយសេចក្ដីឈឺចាប់យ៉ាងខ្លាំង ហើយបើកភ្នែកក្រឡេកមើលទៅជុំវិញបន្ទប់ដេក រួចសំលឹងទ្រឹងនៅនឹងរូបស្រីក្រមុំដ៏មានរូបឆោមស្រស់បស់ម្នាក់ដែលអង្គុយនៅបន្ទប់របស់ខ្លួន ទើបចៅចិត្រហាមាត់ឡើងប្រុងនឹងនិយាយទៅ តែនាងដណ្ដើមនិយាយឡើងមុនថា "ចិត្រ! ចិត្រ រលឹកហើយឬ?" នាងសួរដោយសំដីទន់ផ្អែមល្ហែម!
ចៅចិត្រសួរនាងថា "ខ្ញុំបាទនៅឯណា យុននារី? ចុះហេតុដូចម្ដេចបានជាខ្ញុំបាទមិនស្លាប់?"
នាងតបថា "ចិត្រមិនស្លាប់ទេ ចិត្រចាំមិនបានទេឬ? ទីនេះជាបន្ទប់របស់ចិត្រឯង តែគេបានកែប្រែឲ្យបានស្រួល ដើម្បីឲ្យមានអាកាសល្អឡើង"។
ផ្ការំចេកនៅនឹងដប ចោលក្លិនក្រអូបឈ្ងុយឈ្ងប់ពេញល្វែងបន្ទប់ នារីកិលចូលមកជិតអ្នកជម្ងឺ ហើយសួរ "ពិសាបបរឬទេ ចិត្រ?"
នាយចិត្រគ្រវីមុខយ៉ាងសន្សឹមៗហើយថា "អរគុណច្រើន យុននារី ខ្ញុំចង់ដឹងថា ខ្ញុំបានត្រឡប់មកដល់ទីនេះបានដោយហេតុយ៉ាងណា? ហើយពួកចោរទៅឯណាអស់ទៅ?"
នាងនារីញញឹមប៉ប្រែហើយថា "គឺយ៉ាងនេះ នៅពេលវេលាដែលចិត្រត្រូវចោរបាញ់ដួលសន្លប់ នៅពេលនោះស្រាប់តែតាសុនបររថយន្តមួយធំមកតាមយើង ហើយមានគ្នាច្រើនផង គាត់ប្រាប់ថាឃើញពួកយើងបាត់ទៅយូរពេក គាត់មានសេចក្ដីព្រួយបារម្ភក្រែងមានគ្រោះថ្នាក់តាមផ្លូវ ទើបគាត់សុំខ្ចីរថយន្តម៉ុងថៅងយ៉ុកទៅទទួលយើង ស្រាប់តែប្រទះនឹងពួកយើងកំពុងច្បាំងនឹងពួកចោរ ហើយគាត់ជួយស្រែកហ៊ោបង្អើលពួកចោរ ទាល់តែពួកចោររត់ខ្ចាត់ខ្ចាយចូលព្រៃអស់ទៅ ទើបពួកយើងនាំគ្នាលើកចិត្រដាក់រថយន្តមកផ្ទះនេះ ហើយលោកឪពុកឲ្យមនុស្សទៅអញ្ជើញគ្រូពេទ្យមកពិនិត្យរក្សាអាការរបួសរបស់ចិត្រ ស្ដាប់បានទេ!"។
នាយចិត្រដកដង្ហើមធំដោយអាការធូរក្នុងទ្រូងជាច្រើន សំឡឹងមើលទៅវង់ភក្ត្ររបស់នារី ហើយពោលថា "ខ្ញុំបាទគួរតែស្លាប់នៅក្នុងព្រៃនោះប្រសើរជាង មិនគួរនាំខ្ញុំបាទមកទីនេះទេ ត្បិតនៅទីនេះ ខ្ញុំបាទមុខជាស្លាប់ដោយអាការក្រំចិត្តមិនខាន"
នារី៖ "ចុះហេតុដូចម្ដេចបានជាចិត្រនិយាយយ៉ាងហ្នឹង?" គ្មាននរណាចិត្តអាក្រក់ដល់បណ្ដោយឲ្យស្លាប់ដូច្នេះទេ ចិត្រដឹងទេ ឥឡូវនេះអ្នកណាៗក៏គេស្រឡាញ់ចិត្រទាំងអស់គ្នា លោកឪពុកមាន

ប្រសាសន៍បើចិត្រសះជាហើយ លោកនឹងតាំងឲ្យជាអ្នកត្រួតត្រាមើលអណ្តូងត្បូងទាំងអស់ជំនួសខ្លួនលោក មើលទៅដូចជាលោកពេញចិត្តនឹងចិត្រកាន់តែច្រើនឡើងៗ!”

ថៅចិត្រស្ងៀមទៅមួយស្របក់ ទើបមើលមុខនារី ដោយអាការសោកៗថា “ យុននារី យុននៅចាំសំដីខ្ញុំបាទបានឬទេ កាលគ្រានិយាយគ្នានៅក្រោមដើមស្រទ្បៅក្នុងយប់នោះ?”

នារីញញឹមយ៉ាងស្រស់ទន់ភ្លន់ហើយថា “ចាំ! ចាំបានទាំងអស់ ឥតភ្លេចមួយម៉ាត់ណាសោះ ចុះហេតុអ្វីក៏សួរដូច្នេះ?”

ថៅចិត្រងាកប្រែខ្លួនផ្អៀងបន្តិចហើយថា “ទេ យុន តាមដោយពិតខ្ញុំបាទមិនគួរនិយាយចេញមកសោះ តែដែលហ៊ាននិយាយដូច្នោះក្នុងវេលានោះ ព្រោះគិតជាស្រេចថាមុខជាគ្មានជីវិតរស់នៅក្នុងលោកតទៅទៀតទេ តែឥឡូវនេះបែរជាមិនស្លាប់ នេះហើយដែលធ្វើឲ្យខ្ញុំបាទក្រៀមក្រំក្នុងឱរាត្រាតែអស់ជីវិតមិនខាន”។

នារីយកដៃបិទមាត់ថៅចិត្រជាប្រញាប់ហើយថា “គ្មាននរណាចិត្តអាក្រក់ធ្វើបាបចិត្រឲ្យបានសេចក្តីវេទនាដូច្នោះទេ មនុស្សល្អយ៉ាងនេះ តើនរណាស្អប់ ចិត្រមិនជឿទៀតឬថានារីស្រឡាញ់ចិត្ររបស់នារីយ៉ាងអស់ពីចិត្ត!”។

ថៅចិត្រញញឹមហើយថា “ជឿ ជឿអស់ពីពោះ ប៉ុន្តែនឹងមានប្រយោជន៍អ្វី កាលបើឋានៈរបស់យើងខុសគ្នាឆ្ងាយណាស់ ហាក់ដូចជាមេឃនិងដី!”។

នាងនារីនៅតែស្ងៀម។

ថៅចិត្រនិយាយតទៅទៀតថា “ខ្ញុំជាមនុស្សភ្លើទេ យុន ដូចពាក្យទំនៀមថា “ឆ្កេះកញ្ចក់មិនមើលស្រមោលប្រាណ ដាំជើងក្រានមិនប្រមាណជើងឆ្នាំង” ហេតុតែអន្ទះអន្ទែងដែងបុណ្យភ័ព្វសំណាងនេះហើយ នឹងនាំឲ្យគ្រោះថ្នាក់ដល់ខ្លួនមិនខាន ដូចបុរាណថា “ដៃខ្លីខំប្រវាឱបភ្នំ” មានតែនាំឲ្យក្រៀមក្រំចិត្តឥតប្រយោជន៍ដរាបដល់ ក្ស័យជីវិតមកតែអំពើមានគំនិតឥតកំណើតដូចខ្លួនខ្ញុំបាទនេះឯង” ថាហើយក៏ដកដង្ហើមធំដោយអាការអស់សង្ឃឹម។

នាងនារីសំឡឹងមើលមុខដោយចិត្តអាណិតអាសូរហើយនិយាយថា “គិតច្រើនហួសប្រមាណដោយខ្លួនឯង នារីប្រាប់ហើយថាស្រឡាញ់យ៉ាងអស់ពីចិត្ត ក៏នៅតែមិនជឿទៀត ចុះឲ្យនារីធ្វើដូចម្តេច? នារីព្រមតាមគ្រប់យ៉ាង មិនមានអ្វីក្នុងលោកនេះមកកំចាត់សេចក្តីតាំងចិត្តរបស់នារីបានឡើយ នារីស្រឡាញ់ចិត្រតែម្នាក់នេះឯង មិនមានបុរសគំរប់ជាពីរទៀតទេ នារីមិនត្រូវការអ្វីដទៃទៀតទាំងអស់ក្រៅអំពីសេចក្តីស្រឡាញ់ដ៏ស្មោះត្រង់បរិសុទ្ធរបស់ចិត្រប៉ុណ្ណោះ”។

“មែនឬនារី?” ចិត្រញញឹមយ៉ាងរួសរាយ។

នារីៈ “ពុទ្ធោ! នៅតែមិនជឿទេឬ?” នាងនិយាយដោយទោមនស្សអន់ចិត្ត។

ថៅចិត្រចាប់ទាញដៃនាងនារីមកថើបយ៉ាងស្នេហាអស់ពីចិត្ត នារីក៏ជ្រប់មុខនឹងដើមទ្រូងរបស់ប្រុសកម្លោះសំឡាញ់ សេចក្តីស្នេហាដែលកប់ទុកក្នុងចិត្តមកជាវេលាយូរក៏ខ្ចាយផ្សាយប្រាប់គ្នាទៅវិញទៅមកដោយពិតត្រង់ទាំងអស់ ពីដើមមក នារីធ្លាប់មើលងាយប្រមាថថៅចិត្រ ហើយស្អប់ថៅចិត្រ

តែនៅទីបំផុតនេះ ប្រែជាស្រឡាញ់គេវិញ ហើយជាសេចក្តីស្នេហាស្រឡាញ់យ៉ាងបរិសុទ្ធស្មោះត្រង់ ទន់ផ្អែមត្រជាក់ចេញមកពីបេះដូងដែលថ្លាផូរផង់ខ្ជាប់ខ្ជួន ឥតមានចាស់ទុំបង្ខំចិត្តឡើយ។

នៅឱកាសដែល កំឡោះក្រមុំកំពុងនិយាយចរចាសាស័ព្ទយ៉ាងភ្លើតភ្លើននោះ ស្រាប់តែឮសូរជើងមនុស្សឡើងជណ្តើរមក ទើបនាងនារីបើកទ្វារចេញទៅទទួលលោកហ្លួងរតនសម្បត្តិនិងគ្រូពេទ្យ ជនទាំងពីរក៏ដើរចូលទៅក្នុងបន្ទប់ថៅចិត្រ។ ថៅចិត្រធ្វើអាការហាក់ដូចជានឹងក្រោកឡើង តែលោកហ្លួងលើកដៃហាមថា "កុំក្រោក ដេកតាមសប្បាយចុះ" ហើយងាកទៅសួរគ្រូពេទ្យថា "ថ្ងៃនេះ អាការរោគដូចម្តេចខ្លះ លោកគ្រូ?"
លោកគ្រូពេទ្យ ចាប់ដៃអ្នកជម្ងឺត្រួតសព្វគ្រប់ហើយ ទើបនិយាយថា "គ្រាន់បើឡើងច្រើន ព្រោះគ្រាប់កាំភ្លើងដែលចោរបាញ់ត្រូវគេចផុតពីកន្លែងសំខាន់ៗទាំងអស់"។
លោកហ្លួងនិយាយថា "គ្រោះល្អណាស់! ខ្លួនខ្ញុំនិងកូនខ្ញុំ ប្រសិនបើមិនបានថៅចិត្រជួយការពារក្នុងគ្រានោះទេ មិនដឹងជាដូចម្តេចទេ ចុះប៉ុន្មានថ្ងៃទៀត ទើបបានជាសះស្បើយ លោកគ្រូ?"
លោកគ្រូពេទ្យសំលឹងមើលនាងនារី ហើយញញឹមនិយាយថា "ខ្ញុំបាទគិតថា បើមានអ្នកថែរក្សាជំងឺចំណាប់ចំនួនបែបនេះ គង់សះជាឆាប់រហ័សមិនខាន តែវេលានេះតោងឲ្យអ្នកជម្ងឺដេកឲ្យស្ងៀម ទម្រាំឲ្យរបួសសះល្អសិន"។
ឯនាយចិត្រសំដែងសេចក្តីអរគុណដល់លោកហ្លួងនិងគ្រូពេទ្យហើយ លោកទាំងពីរក៏នាំគ្នាដើរចេញទៅ ឯហ្លួងរតនសម្បត្តិងាកមកប្រាប់ថៅចិត្រថា "តាំងពីថ្ងៃនេះតទៅ ទុកជាថៅចិត្រសះជាខ្លួនហើយក៏មិនបាច់ធ្វើការនៅអណ្តូងត្បូងដូចមុនៗទៀតទេ ខ្ញុំតាំងឲ្យអ្នកឯងជាជំនួសខ្ញុំ ត្រួតមើលអស់ទាំងអណ្តូងដែលពួកកម្មករជីកមកទាំងប៉ុន្មាន រៀបចំតាមប្រភេទរបស់ត្បូង មិនបាច់ទៅធ្វើការធ្ងន់ដូចសព្វដងទេ ក្រែងនាំឲ្យជំងឺរើឡើងវិញ" រួចលោកគ្រូពេទ្យនិងហ្លួងរតនសម្បត្តិ នាំគ្នាដើរចុះពីផ្ទះទៅ។

ដោយហេតុនាងនារីយកចិត្តទុកដាក់ថែរក្សាព្យាបាលជំងឺដោយផ្ចិតផ្ចង់ ទើបជំងឺថៅចិត្រមានអាការគ្រាន់បើឡើងជាលំដាប់ ហើយនៅទីបំផុតក៏បានសះជាដូចប្រក្រតី ថែមទាំងឥឡូវនេះ មិនបាច់ចេញទៅជីកត្បូងបែកញើសតាងទឹកដូចពីមុនទៀតផង គ្រាន់តែជួយចាត់ចែងធ្វើបញ្ជីត្បូង ដែលពួកកម្មករជីកបានមកពីអណ្តូងផ្សេងៗ ព្រមទាំងបើកប្រាក់ខែឲ្យពួកកម្មករ ទើបនាំឲ្យថៅចិត្របានសេចក្តីសុខឡើងទៀតជាច្រើន សុខទាំងកាយ សុខទាំងចិត្ត គឺថាស្រុកបប៉ៃលិនទុកជាស្ថានសួគ៌របស់ថៅចិត្រតែម្តង ហើយគេតែគិតជានិច្ចថា នឹងតាំងខ្លួនប្រាណឲ្យបានខ្ជាប់ខ្ជួន ត្រាតែដល់នូវវារៈបំផុតនៃជីវិតិន្ទ្រីយ៍។

ថ្ងៃនេះ អាកាសភ្លឺស្រឡះល្អមានខ្យល់បក់រំភើយៗល្មមតែត្រជាក់ស្រួល នារីបបួលថៅចិត្រចុះទៅអង្គុយនិយាយគ្នាលេងនៅក្នុងសួនច្បារក្រោមផ្ទះ ស្តាប់សូរស័ព្ទបក្សាបក្សី ស្រែកយំតាមភាសារបស់វា ជាទីកំសាន្តចិត្តរបស់អ្នកដែលមានមេត្រីស្នេហាដល់គ្នា។

ថៅចិត្រនិយាយតិចៗ កាលឃើញនាងនារីនៅស្ងៀមថា "យុននារី"។

នារី៖ "ចា៎!" នាងញញឹមយ៉ាងទន់ភ្លន់ហើយថា "នៅជាមួយចិត្រយ៉ាងនេះ នារីមានសេចក្តីសុខយ៉ាងលើសលន់តែម្តង!"។

គេញញឹមប៉ប្រែ ហើយថា "មិននឹកសោះឡើយថា ទេវតាប៉ៃលិនប្រោសប្រាណបងដល់ម្លេះទេ" នាងធ្វើជាសំឡក់តាមមាយាស្ត្រី ហើយស្រដីថា "ដឹងថាគេស្រឡាញ់ខ្លួនបន្តិច ក៏តាំងអួតយ៉ាងសំបើមតែម្តងហ្ន៎!"

ចិត្រ៖ "ចុះស្អប់បងណាស់ឬអី?"។

នារី៖ "ស្អប់ណាស់" នាងតបចាក់បណ្តោយ។

ថៅចិត្រញញឹមប៉ប្រឹមហើយថា "បើស្អប់បងណាស់ ម៉េចក៏មិនទុកចោលឲ្យស្លាប់នៅក្នុងព្រៃនោះទៅ" នាងបែរមកសំឡក់ហើយថា "ដោយគេអាណិតបន្តិចទេតើ កុំអីត្បាតផ្តុំខ្លួយក្នុងព្រៃនោះទៅហើយ"។

ស្ងៀមទាំងអស់គ្នាទៅមួយស្របក់ ថៅចិត្រក៏ចាប់និយាយឡើងជាមុនថា "អើ! យុននារី លោកឪពុកបានជ្រាបរឿងរ៉ាវរបស់យើងខ្លះដែរឬនៅឡើយទេ?"

នារី៖ "មិនទាន់ជ្រាបទេ"។

ចិត្រ "បើលោកជ្រាប មុខជាលោកធ្វើទោសបំបរបង់ដូចម្តេចមិនដឹងទេ បងព្រួយចិត្តណាស់!"

នារី៖ "រឿងនេះខ្ញុំដឹងមិនដល់ទេ ព្រោះលោកមិនដែលឮនិយាយដូចម្តេចសោះឡើយ"។

ថៅចិត្រនិយាយដោយទឹកមុខស្រពោនថា "ប្រសិនបើលោកជ្រាប មុខជាដេញបងឲ្យចេញពីផ្ទះនេះមិនខាន"។

នារីសំឡក់ដាក់ទៅចិត្រម្តងទៀតហើយនិយាយ "ឆ្អើមសំដីបងឯងណាស់ បងចិត្រ លោកពុកមិនមែនចិត្តអាក្រក់ដល់ម្លេះទេ លោកចាស់ទុំហើយ តែងតែស្គាល់ឫទ្ធិអំណាចសេចក្តីស្នេហាច្បាស់លាស់ជាងក្មេងៗទៅទៀត"។

ចិត្រ៖ "ឯបងជាមនុស្សកំសត់ទុគ៌ត ឥតទ្រព្យសម្បត្តិទាំងកំព្រីកំព្រាផង មានតែជីវិតនិងរាងកាយប៉ុណ្ណោះ"។

នារី៖ "ប៉ុណ្ណឹងក៏ល្មមគ្រប់គ្រាន់ហើយ"។

ចិត្រ៖ "គ្រប់គ្រាន់តែចំពោះអូននារីប៉ុណ្ណោះ"។

នារី៖ "ទោះបីលោកពុក ក៏មិនត្រូវការអ្វីទៀតដែរ"។

ចិត្រ៖ "ចុះប្អូននារីដឹងចិត្តលោកបានឬ?"។

នារី៖ "ចា៎ ដឹងខ្លះដែរ ធម្មតាឪពុកនិងកូននៅជាមួយគ្នាយូរអង្វែងណាស់មក ហើយតែងតែដឹងគ្នាខ្លះមិនខាន កុំថាគ្រាន់តែដឹងចិត្តលោកឪពុកម្នាក់ឡើយសូម្បីតែ ..."។

"ចិត្តរបស់បង ប្អូននារីក៏ដឹងទាំងអស់ដែរ" ចៅចិត្រនិយាយបញ្ចប់ប្រយោគ។
នារី សំឡក់ហើយថា "ដឹងខ្លួនទេ បងប៉ិនកុហកលេខមួយ?"
ចិត្រ៖ "បងកុហកប្អូនដូចម្ដេច?" ធ្វើមុខដូចជាឆ្ងល់។
នារី៖ "កុំធ្វើពើឡើយ លោកពូកូនសិស្សសាលាវត្ត"។
ចិត្រ៖ "ក៏បងរៀនសាលាវត្តមែននេះណា៎!"
នារី៖ "ចុះសាលាវត្ត គេមានរៀនដល់ប្រវត្តិពង្សាវតារលោក ភូមិសាស្ត្រវិទ្យាសាស្ត្រទំនើបថ្មីដែរឬ?"
ចិត្រ៖ "ទេ" ឆ្លើយធ្វើមុខព្រងើយ។
នារីនាងផ្ទួនពាក្យថា "តែខ្ញុំបានឃើញសៀវភៅអស់នេះនៅក្នុងបន្ទប់របស់បងឯង ហើយមានស៊ីញ៉េឈ្មោះបងឯងជាភាសាបារាំងផង"។
ចៅចិត្រមិនឆ្លើយគ្រាន់តែញញឹម។
នារី៖ "ប៉ិនភូតដូចសព្វដង នេះនែ! បងចិត្រ! ចុះកាលណាបងឯងចោលនិស្ស័យរឹងរូសចេញ បើនៅតែកុហកខ្ញុំទៀត ខ្ញុំនឹងខឹងច្រើនតែម្ដង"។
ចៅចិត្រខិតចូលទៅកាន់តែជិត ហើយថា "ប្អូននារីហ៊ានខឹងនឹងសង្សារកំសត់បានឬ?"
"មិនជឿនឹងលមើលក៏បាន នារីអាចនឹងស្អប់ប៉ុនគ្នានឹងស្រឡាញ់ក៏បាន"។
ចៅចិត្រសើចយ៉ាងសប្បាយចិត្តហើយថា "បងក៏ដឹងថាប្អូននារីមិនស្អប់បងទេ"។
នារី៖ "ចុះហេតុអី?"
ចិត្រ៖ "ក៏ប្អូននារីប្រាប់ថាស្រឡាញ់បងដែរមែនទេ?"
នារីលូកដៃមួលភ្លៅចៅចិត្រទាល់តែស្រែក ទើបនាយចិត្រអោបក្រសោបដៃនារីហើយ ពោលថា "ម្ដងនេះបងលែងកុហកប្អូនទៀតហើយ ត្បិតគ្រប់យ៉ាងគ្រប់ប្រការ យើងបានដឹងគ្នាច្បាស់លាស់ហើយ មែនទេប្អូននារី?"
នាងសំឡឹងមើលមុខគេដោយមេត្រីចិត្ត ហើយផ្លាស់និយាយពីរឿងផ្សេងៗថា "អេ៎! បងចិត្រ ឥឡូវនេះត្បូងរបស់យើងដូចម្ដេចខ្លះ?"
ចៅចិត្រឆ្លើយថា "ឥឡូវចំរើនឡើងច្រើន អណ្ដូងត្បូងទិសខាងកើតជីកបានត្បូងទឹកធម្មតាជាងដប់គ្រាប់ អណ្ដូងខាងលិចជីកបានត្បូងទឹកយ៉ាងល្អ៦ទៅ៧គ្រាប់ ឥឡូវត្បូងទាំងអស់របស់យើងមានចំនួនជាង២០០គ្រាប់ បើគិតទៅមានតម្លៃជាង១ម៉ឺនរៀល"។
ក្រមុំកម្លោះទាំងពីរនិយាយសំណេះសំណាលសារសេងគ្នាទៅវិញទៅមកយ៉ាងក្សេមក្សាន្តសឹងពោរពេញដោយសេចក្ដីស្នេហាក្នុងគ្រានោះ គេឥតនឹកនាអំពីសេចក្ដីលំបាកក្នុងការចិញ្ចឹមជីវិតបន្តិចឡើយ គិតតែសប្បាយរីករាយក្នុងការផ្ដេកផ្ដិត សំរួលកាយសំរួលចិត្តទៅតាមព្រះហឫទ័យនៃព្រះកាមទេពជាម្ចាស់ដែលទ្រង់មានឫទ្ធិជាពន្លឹកលើដួងចិត្តនៃក្រមុំកំឡោះទាំងឡាយក្នុងលោកិយនេះ។

# វគ្គទី៦

## គេហដ្ឋានរតនសម្បត្តិត្រូវចោរប្លន់

នៅក្នុងថ្ងៃមួយនោះ ជាវេលារសៀលម៉ោងប្រហែល៤ នាងនារីនិងថៅចិត្រកំពុងអង្គុយធ្វើបញ្ជីត្បូង នៅក្នុងបន្ទប់ធ្វើការ នាងនារីផ្ដើមនិយាយឡើងថា "តាំងពីបងចិត្រមកនៅធ្វើការជាជំនួយលោកឪពុកកាលណា កិច្ចការក៏ចំរើនឡើងច្រើនជាងពីដើម" នាងនិយាយដោយសុចរិត ហើយនឹងចាប់និយាយតទៅទៀត ស្រាប់តែឮសូរសម្លេងរថយន្តមួយមកចតនៅមុខផ្ទះរតនសម្បត្តិ ថៅចិត្រក៏ស្ទុះក្រោកឡើង ទៅមើលតាមចន្លោះបង្អួច ហើយត្រឡប់មកអង្គុយកន្លែងដើមវិញ។

នារី៖ "បងចិត្រ អ្នកណាមកហ្នឹង?"

ចិត្រ៖ "បាឡាត់ស្រុកសង្កែ តែម្នាក់ទៀតបងមិនស្គាល់ទេ"។

នារី៖ "អេ៎! គេមករកអ្វី? ចុះបងចិត្រ មិនទៅទទួលភ្ញៀវជំនួសលោកឪពុកផង"

ថៅចិត្រក្រោកឡើងដើរចេញ នាំនាងនារីអោយដើរតាមទៅផង ឯលោកបាឡាត់ឈរយ៉ាងអង់អាចនៅខាងមុខផ្ទះជាមួយនឹងបុរសម្នាក់ទៀត មានរាងមាំខ្មៅ សក់ក្រញាញ់ ភ្នែកក្រលួង។

ថៅចិត្រដើរចូលទៅសួរយ៉ាងសុភាព "ទានប្រោស លោកអញ្ជើញមករកអ្នកណា?"

តែលោកបាឡាត់គ្រាន់តែញាក់មុខ ហើយងាកទៅទទួលសំពះនាងនារីដែលឈរពីក្រោយថៅចិត្រ រួសរាយប្រស្រ័យនឹងនាងដោយឥតរវល់នឹងថៅចិត្រដែលឈរជ្រងោ នៅចំពីមុខនោះឡើយ។

បាឡាត់៖ "លោកឪពុកនៅទេ យុននារី?"

នារី៖ "ចា៎នៅ! មើលទៅលោកប្រហែលជានៅក្នុងបន្ទប់មើលសៀវភៅខាងលើ ចុះលោកបាឡាត់មានធុរៈអ្វី?"

បាឡាត់៖ "បាទ មានខ្លះដែរ គឺខ្ញុំបាទនាំថៅកែផាន់មកទិញត្បូងដើម្បីយកទៅលក់ឯព្រៃនគរ" លោកបាឡាត់តបហើយខំញញឹមអោយស្រស់ តែត្រឡប់ទៅជាទាស់ភ្នែករបស់ថៅចិត្រជាបំផុត។

នាងនារីញញឹមទទួលដោយកិរិយាទន់ភ្លន់ ហើយនិយាយថា "អញ្ជើញលោកឡើងទៅខាងលើ ឲ្យជួបនឹងប៉ានិយាយថ្លៃគ្នាចុះ" ថាហើយ នាងក៏ដើរនាំមុខភ្ញៀវឡើងទៅលើផ្ទះថ្នាក់លើ ជួបនឹងលោកហ្លួងកំពុងដេកមើលសៀវភៅនៅលើកៅអីផ្តៅ លោកក៏ក្រោកឡើងនិយាយរាក់ទាក់ដោយសេចក្តីស្និទ្ធស្នាលថា "អា៎! លោក បាឡាត់ឬ? អញ្ជើញ! អញ្ជើញមកខាងនេះ ចុះលោកមានធុរៈអ្វី?"

បាឡាត់៖ "ខ្ញុំបាទនាំថៅកែផាន់មកទិញត្បូង" លោកបាឡាត់ឆ្លើយព្រមទាំងទាញកៅអីមួយអោយថៅកែផាន់អង្គុយ ខ្លួនឯងក៏អង្គុយលើកៅអីមួយក្បែរខាងនាងនារី ឯថៅចិត្រឈរឃ្លាតឆ្ងាយពីនោះបន្តិច ដ្បិតមិនទាន់ទុកចិត្តមនុស្សចំណូលថ្មី រាងធំ ភ្នែកក្រឡោត ដែលឈ្មោះថាថៅកែផាន់នោះសោះ។

ហ្លួងរតនសម្បត្តិងាកទៅខាងថៅកែផាន់ហើយសួរថា "ថៅកែត្រូវការទិញត្បូងបែបណា?"
ផាន់៖ "ខ្ញុំបាទតោងសុំពិនិត្យមើលសិន បើត្រូវចិត្តខ្ញុំបាទនឹងនិយាយថ្លៃទិញយកទៅលក់ឯព្រៃនគរ"។
ហ្លួង៖ "បាទ បានថៅកែ វេលានេះ ត្បូងមានច្រើនពណ៌ផ្សេងៗ ទឹកល្អទាំងអស់" ហើយលោកហ្លួងងាកទៅខាងថៅចិត្រ ប្រាប់ថា "ចិត្រ ទៅយកត្បូងមកឲ្យថៅកែពិនិត្យមើលបន្តិចមើល!"។
ថៅចិត្រដើរចូលទៅក្នុងបន្ទប់បាត់ទៅ មួយស្របក់ត្រឡប់មកវិញ កាន់ហឹបត្បូងដែលឆ្នៃហើយ ២-៣ ហឹប យកទៅដាក់លើតុ ហើយបើកបង្ហាញថៅកែផាន់។
ថៅកែផាន់និងលោកបាឡាត់បើកភ្នែកគ្រលួងកាលដែលបានឃើញត្បូងពណ៌ផ្សេងៗក្នុងហឹបនេះ មានចំនួនដល់ទៅជាង២០០គ្រាប់ ថៅកែផាន់ចាប់លើកឡើងពិនិត្យមើលដោយប្រុងប្រយ័ត្ន ហើយដាក់ទៅវិញនិយាយថា "ត្បូងអស់នេះ ទឹកល្អមែន ប្រហែលជាមានតម្លៃច្រើន?"
លោកហ្លួង គ្រវីក្បាលហើយថា "មិនសូវជាថ្លៃប៉ុន្មានទេ មានតំលៃថោកជាងឯព្រៃនគរច្រើន"។
រួចថៅកែផាន់ចាប់មួយគ្រាប់លើកឡើងមើលម្តងទៀត ហើយសួរថ្លៃថា "ទានប្រោស មួយគ្រាប់នេះតំលៃប៉ុន្មានទៅ?"
ហ្លួង៖ "យ៉ាងនេះទឹកល្អច្រើន ១ក្រាត់ ថ្លៃ២០០រៀល ក្នុង១គ្រាប់នេះ ប្រហែលជា៤ក្រាត់"។
ផាន់៖ "ទានប្រោស ថ្លៃបន្តិច បើចុះបន្តិចទៅទៀតបានទេ?"
ហ្លួង៖ "មិនជាអ្វីទេ បើថៅកែត្រូវការក៏ចុះជូនឲ្យបានខ្លះ ដោយសេចក្តីរាប់អានគ្នា"។
ផាន់៖ "ចុះថ្លៃប៉ុន្មាន?"
លោកហ្លួងចាប់ត្បូងនោះមកពិនិត្យមើលម្តងទៀតហើយថា "បែបនេះចុះជូនបាន១ក្រាត់ ២០រៀល"។
ថៅកែផាន់មើលមុខលោកបាឡាត់ ជាទំនងសូមឲ្យជួយគិតគូរតថ្លៃផង។ ឯលោកបាឡាត់ញាក់មុខប្រាប់ថា "គួរសមហើយថៅកែ ព្រោះត្បូងបែបនេះ មិនងាយរកទេក្នុងវេលានេះ"។
ថៅកែក៏ញញឹមឃើញធ្មេញស្ញេញ ហើយនិយាយតថ្លៃនឹងហ្លួងថា "រឿងនេះទុកជាស្រេចទៅចុះ តែវេលានេះ ខ្ញុំបាទមិនបានយកប្រាក់មកទេ ដល់ព្រឹកស្អែក ខ្ញុំបាទនឹងយកប្រាក់មកជូន ហើយទទួលត្បូងទៅផង មើលទៅប្រហែលជាត្រូវការចំនួនច្រើនគ្រាប់ផង"
ហ្លួង៖ "បាទ បាន! អង្កាលក៏បាន ខ្ញុំនៅផ្ទះជាដរាប បើអញ្ជើញមកគង់តែជួបខ្ញុំជានិច្ច"។
ថៅកែផាន់និយាយដោយអោនលំទោន "សូមអរគុណ តែខ្ញុំបាទសូមឲ្យលោកមេត្តាបន្តិច ដ្បិតខ្ញុំបាទមិនដែលឃើញរបៀបជីកត្បូងសោះ សូមលោកបើកឱកាសឲ្យខ្ញុំបាទទៅមើលបានឬទេ?"
លោកហ្លួងសើចហើយថា "បាទ បាន! ថៅកែ ខ្ញុំមិនកំណាញ់ទេ មានអណ្តូងត្បូងនៅក្បែរៗផ្ទះនេះក៏មាន នៅខាងក្រោយផ្ទះនេះឯង អញ្ជើញទៅមើលបានតាមត្រូវការ"។
លោកហ្លួងក៏ក្រោកចេញពីកៅអីហើយថា "អញ្ជើញមកតាមខ្ញុំ ថៅចិត្រ ទៅជាមួយផង"។
ថៅចិត្រមិនចង់ចេញចោលពីនាងនារីឡើយ គេក្រឡេកមើលបាឡាត់ស្រុកនោះដោយកិរិយាមិនទុកចិត្តសោះ ហើយសួរទៅថា "សូមទោស លោកមិនអញ្ជើញទៅមើលទេឬ?"
លោកបាឡាត់ គ្រវីក្បាលហើយថា "មិនទៅទេ ធ្លាប់មើលរាប់រយដងហើយ"

ឯនាងនារីក្រោកឡើង ប្រុងនឹងដើរតាមចៅចិត្រទៅដោយនាងដឹងចិត្តរបស់គូស្រករនាងយ៉ាងច្បាស់ តែបាឡាត់ស្រុកឃាត់នាងថា "ប្រញាប់អញ្ជើញទៅណា យុននារី ទុកខ្ញុំបាទឲ្យអង្គុយងក់តែម្នាក់ឯងឬអី?"

នាងនារីបែរចេញមកញញឹមតាមទំនៀម ទាំងមិនដោះសាថាអ្វីក៏ដាក់គូថអង្គុយលើកៅអីដដែល ដោយនឹកក្រែងចិត្តភ្ញៀវហើយសួរថា "លោកបាឡាត់មានរឿងអ្វីនិយាយនឹងខ្ញុំឬ?"

កាលបាឡាត់ស្រុកនោះឃើញចៅចិត្រចេញផុតទ្វារទៅហើយ ក៏លើកកៅអីចូលមកជិតនាងនារី ហើយក៏ញញឹមប៉ប្រិម រួចនិយាយថា "រឿងរបស់ខ្ញុំមានច្រើនណាស់"។

"មានរឿងអ្វីខ្លះ អញ្ជើញមានប្រសាសន៍ទៅចុះ ខ្ញុំនឹងចាំស្ដាប់"។

បាឡាត់ស្រុកសំឡឹងមើលនាងនារីដោយទឹកមុខចំឡែក ហើយនិយាយតិចៗស្ទើរតែទៅជាខ្សឹបថា "យុននារី ខ្ញុំមានរឿងសំខាន់ណាស់ដែលត្រូវនិយាយផ្ទាល់ខ្លួនយុន!"។

នាងនារីអង្គុយនៅតែស្ងៀម លោកបាឡាត់ក៏និយាយតទៅថា "ជារឿងសំខាន់ស្មើជីវិតរបស់ខ្ញុំតែម្ដង ដ្បិតជីវិតខ្ញុំវេទកម្មយូរណាស់មកហើយ!"

ទើបនាងនារីដឹងខ្លួនថា បាឡាត់នោះនិយាយចែចង់ខ្លួននាងហើយ តែធ្វើជាមិនដឹងរឿងរ៉ាវអ្វី នៅតែស្ងៀមដូចប្រក្រតី។

បាឡាត់៖ "យុននារី"។

នារី៖ "ចា៎!"

បាឡាត់៖ "មេត្តាជួយសង្គ្រោះខ្ញុំបាទផងបានទេ?"

នារី៖ "ចុះនឹងឲ្យជួយលោកបាឡាត់ដូចម្ដេចខ្លះ?"

បាឡាត់៖ "បើយុនស្ម័គ្រជួយមែន មុខជាបានផលជាប្រាកដ"។

នារី៖ "លោកបាឡាត់មិនទាន់ប្រាប់រឿងឲ្យខ្ញុំដឹងថាត្រូវឲ្យខ្ញុំជួយដូចម្ដេច?"

បាឡាត់៖ "គង់តែនឹងប្រាប់យុនឥឡូវនេះហើយ តែយុនត្រូវធ្វើសញ្ញាថា បើសំដីដែលខ្ញុំនិយាយទៅនេះមិនជាទីគាប់ចិត្តទេ សូមយុនត្រាប្រណីកុំបីប្រកាន់ខឹងឡើយ"។

នារី៖ "ចា៎! ខ្ញុំមិនខឹងនឹងលោកបាឡាត់ផ្ដេសផ្ដាសទេ"។

បាឡាត់ខិតចូលទៅជិតនាងនារី ហើយនិយាយស្ទើរតែខ្សឹបថា "ខ្ញុំបាទស្រឡាញ់យុនណាស់! យុននារី"

នាងនារីចងចិញ្ចើមទាំងសងខាងភ្លាម។

បាឡាត់ មើលមុខនាងនារី ហើយថា "ប្លែកណាស់ឬយុននារី?"

នារីញាក់មុខ ហើយថា "ខ្ញុំប្លែកណាស់តែម្ដង!"

បាឡាត់៖ "យុនឃើញសេចក្ដីមេត្រីស្នេហារបស់ខ្ញុំបាទជាការចំលែកណាស់ទៅឬ?"

នារីៈ "ទេ! លោកបាឡាត់ ខ្ញុំនឹកឆ្ងល់ ដ្បិតមិនធ្លាប់នឹកនាថាលោកបាឡាត់ចង់ចងមេត្រី ស្រឡាញ់ស្រីដូចជាខ្ញុំនេះឡើយ"។

បាឡាត់ៈ "តែខ្ញុំបាទវិញឥតនឹកឆ្ងល់បន្តិចក្នុងការមកចងមេត្រីនឹងស្រីដូចរូបយុនដែលមានលក្ខណៈល្អគ្រប់បែបយ៉ាង" ថាហើយ ក៏ឈោងដៃចាប់ដៃនាង តែនាងរលាស់ដៃចេញទៅ។
នារីៈ "ខ្លួនខ្ញុំឥតមានអ្វីល្អទេ លោកបាឡាត់"
លោកបាឡាត់សើចហ៊ឺៗ ហើយថា "កុំនិយាយបន្ទាបបន្ថុះខ្លួនឡើយ យុន មុនខ្ញុំនឹងមកនិយាយជាមួយនឹងយុន ខ្ញុំបាទគិតហើយគិតទៀតជាច្រើនត្រឡប់ នៅទីបំផុតក៏ដាច់ចិត្តមកនិយាយនឹងយុន"។
នារីៈ "ចុះលោកដាច់ចិត្តយ៉ាងម្ដេច?"
បាឡាត់ៈ "ដាច់ចិត្តថាត្រូវមកជំរាបឲ្យយុនបានជ្រាប ថាខ្ញុំបាទស្រឡាញ់យុន ជាសេចក្ដីស្រឡាញ់ពិតប្រាកដដ៏បរិសុទ្ធចេញពីបេះដូងរបស់ខ្ញុំបាទ ចុះខាងយុន តើអាចតបានឬទេថាយុនក៏ស្រឡាញ់ខ្ញុំបាទខ្លះដែរ?"
លោកបាឡាត់និយាយយ៉ាងទន់ភ្លន់ ពិរោះស្ដាប់ តែនាងនារីនៅតែយល់ថា ចៅចិត្ររបស់នាងនិយាយពិរោះជាងនេះទៅទៀត ទើបនាងឆ្លើយទៅវិញថា "រឿងនេះ ខ្ញុំតបលោកបាឡាត់មិនបានទេ"។
លោកបាឡាត់ បើកភ្នែកធំៗហើយថា "ព្រោះហេតុអ្វីបានជាតបពាក្យខ្ញុំបាទមិនបាន?"
នារីៈ "ព្រោះខ្ញុំមិនស្រឡាញ់លោកបាឡាត់ទេ"
បាឡាត់ៈ "ចុះហេតុអីមិនស្រឡាញ់ខ្ញុំសោះ" គេសួរនាងនារីដោយសំដីរឹងៗជាងមុនបន្តិច។
នារីៈ "មិនបាច់តបទេ លោកបាឡាត់ ការសំខាន់គឺថាមិនមានចិត្តស្រឡាញ់លោកបាឡាត់ ត្រឹមប៉ុណ្ណោះក៏ល្មមហើយ"។
បាឡាត់ៈ "ពុទ្ធោ យុននារី! យុននឹងសម្លាប់ដោយឥតចិត្តអាណិតអាសូរសោះឡើយឬ?"
នាងនារីមិនតប។
បាឡាត់ៈ "យុនកំពុងតែទំលុះទំលាយបំផ្លាញបំណងល្អនិងសេចក្ដីមេត្រីស្នេហាដ៏សុចរិត ស្មោះត្រង់របស់ខ្ញុំបាទក្នុងខណៈនេះហើយឬ?"

នារីៈ "មិនមែនដូច្នេះទេ លោកបាឡាត់ ស្ត្រីដទៃទៀតដែលល្អជាង គ្រាន់បើជាងក៏មានគរគោកម៉េចក៏លោកមិនស្រឡាញ់?"
បាឡាត់ៈ "ខ្ញុំបាទសូមធ្វើជីវិតចំពោះយុនតែមួយប៉ុណ្ណោះ"
នារីៈ "បើលោកបាឡាត់នៅតែប្រកាន់ដូច្នោះ គង់តែឃ្លាងទាំងអស់មិនបានអ្វីឡើយ"។

លោកបាឡាត់ទាល់ច្រក ក៏ក្រោកដើរវិលវល់តែក្នុងបន្ទប់នោះ ត្រិះរិះរកសំដីនិយាយ។
នាងនារីដើរទៅឯបង្អួចចោលភ្នែកក្រឡេកមើលទៅឯក្រោយផ្ទះ ចាំមើលផ្លូវចៅចិត្ររបស់នាង ដោយនឹករំខានចិត្តនឹងបាឡាត់កម្លោះនេះជាពន់ពេក។
ឯលោកបាឡាត់នោះក៏ដើរទៅឈរពាំងពីខាងមុខនាង ហើយនិយាយថា " ខ្ញុំដឹងហើយ ហេតុអ្វីបានយុនមិនស្រឡាញ់ខ្ញុំ"។
ឯនាងនារី ឈរនៅតែស្ងៀម ដ្បិតនាងមិនត្រូវការស្ដាប់សំដីវាចាបាឡាត់នោះឡើយ។
បាឡាត់៖ "យុនមិនស្រឡាញ់ខ្ញុំ ព្រោះយុនមានតួមនុស្សដែលយុនស្រឡាញ់រួចទៅហើយមែនឬទេ?" គេនិយាយសើចដោយកិរិយាចំអកចំទយ។
នារីងាកខ្ទាប់មកមួយរំពេច ខឹងណាស់ដែលគេនិយាយមិនក្រែងចិត្តនាងសោះឡើយ ហើយនិយាយចេញទៅជា "ប្រយ័ត្នលោកបាឡាត់ មនុស្សដែលលោកថានោះគឺនរណា? កុំប្រើសំដីឈ្លានពានមកលើខ្ញុំខ្លាំងពេកណា!"។
លោកបាឡាត់កាន់តែសើចខ្លាំងឡើងទៀតហើយថា "ខ្ញុំមិនឈ្លានពានបង្កាច់យុនអ្វីទេ គ្រាន់តែនិយាយថាយុនមានគូស្រករបស់យុនរួចទៅហើយ ខ្ញុំនឹងប្រាប់ឈ្មោះឥឡូវក៏បាន"។
នារី៖ "នរណាហ្នឹះ?" នាងសួរទាំងខឹង។
បាឡាត់៖ "គឺចៅចិត្រនោះឯង! មែន ចៅចិត្រវាក្មេងកម្លោះរូបស្រស់សំដីផ្អែម តែវាទីទ័លក្រដូចមនុស្សសុំទានគេ មែនទេ!" (ថាហើយក៏សើចក្អាកក្អាយ)។
នារី "លោកអួតខ្លួនវិសេសវិសាលយ៉ាងណា បានជាហ៊ាននិយាយសង្កត់សង្កិនបន្ថុះបង្អាប់គេយ៉ាងនេះ? បើទុកជាគេទីទ័លក្រក៏ទីទ័លតែទ្រព្យសម្បត្តិប្រាក់មាស តែគុណសម្បត្តិ សុខភាពរៀបរយជាសុភាពបុរស ជាកូនប្រុសមែនៗនោះ ចៅចិត្រមានសព្វគ្រប់ ឯខ្លួនលោកមានតែប្រាក់មាសមែនហើយ លោកអាចទិញដូររបស់អ្វីបានតាមត្រូវការ តែលោកមិនអាចយកប្រាក់មកទិញសេចក្ដីស្នេហារបស់ខ្ញុំបានទេ! លោកមានប្រាក់មាសដែលចៅចិត្រគ្មាន តែរបស់ដែលចៅចិត្រមាន លោកមិនមានសោះឡើយ មែនឬទេ?"
បាឡាត់៖ "ចុះខ្ញុំមិនមានអ្វី? នៅខ្វះអ្វីទៀត?"
នារី៖ "សុភាពបុរសនិងសភាវៈជាកូនប្រុស"។
បាឡាត់៖ "ក៏នេះមិនមែនកូនប្រុសទេឬ?"
នាងនារីសើចចំអកឲ្យហើយវាចា "ត្រូវហើយ តែលោកបាឡាត់ គ្រាន់តែមានរាងកាយជាកូនប្រុស តែចិត្តរបស់លោកបាឡាត់ ខ្លាចលើសស្រីទៅទៀតមែនទេ?"
បាឡាត់៖ "ខ្លាចលើសស្រីទៅទៀត!" និយាយផ្ទួនពាក្យ ហើយសួរទៅទាំងខឹងថា "ចុះហេតុអ្វីក៏យុនហ៊ាននិយាយប្រមាថខ្ញុំដូច្នេះ?"
នារី "ខ្ញុំឥតមាននិយាយប្រមាថកាតទានអ្វីលោកទេ តែនិយាយតាមត្រង់ទេតើ លោកភ្លេចហើយឬកាលចោរប្លន់នៅកណ្ដាលព្រៃ អ្នកណាហ៊ានចេញទៅតទល់ជាមួយចោរ? ហើយអ្នកណារត់ទៅពួន

យកតែព្រះអាយុនៅក្រោមរថយន្ត?"
បាឡាត់៖ "ខណៈនោះវាគ្មានកាំភ្លើងនៅនឹងខ្លួនខ្ញុំទេ យុនក៏ដឹងស្រាប់ហើយ"
នារីសើចហើយថា "បើទុកជាមានក៏មិនហ៊ានបាញ់ដែរ មនុស្សកម្លាចបែបនេះតែរត់បាតជើងសព្រាត ឲ្យរួចខ្លួនប៉ុណ្ណោះ!"
លោកបាឡាត់ កាលត្រូវសំដីស្រីប្រមាថមើលងាយដូច្នេះ ក៏បើកភ្នែកក្រឡោត ប្រឡោតខឹងជាខ្លាំង រួចចាប់ដៃនាងនារីទាំងពីរច្របាច់ណែនហើយប្រាប់ថា "ឈប់និយាយទៀត ខ្ញុំនឹងសងសឹកអំនួតយុន ឥឡូវនេះឯង"
នាងនារីខំរលាស់ចេញជាប្រញាប់ តែលោកបាឡាត់កាន់តែច្របាច់ខ្លាំងឡើងទៀត ហើយស្រវាអោប នាងផង។
នារី៖ "លែងខ្ញុំ! លោកបាឡាត់ លោកមានអំណាចដូចម្ដេចបានហ៊ានធ្វើដូច្នេះ ហ៊ឺះ!" (នារីស្រែកឡើង)។
បាឡាត់៖ "មិនអួតទេ តែហ៊ានធ្វើព្រោះស្រឡាញ់ទេតើ! អោយខ្ញុំថើបដោយស្រួលទៅ!" ហើយខំប្រអោបនារីយ៉ាងណែន។
នាងនារីក៏ខំបម្រះពេញកម្លាំង ទៅជាចំបាប់ប្រចាប់គ្នាអឹកធឹកឡើង ទាល់តែទ្វារបន្ទប់របើក លេចចេញរាងកាយថៅចិត្រស្ទុះបាញ់ត្រង់សំដៅទៅលោកបាឡាត់ ចាប់កន្ត្រាក់លោកបាឡាត់នោះចេញ។ លោកបាឡាត់ភ្លាត់ចំណាប់ មិនបានការពារខ្លួន ទើបត្រូវថៅចិត្រដាល់ដួលផ្ងាចង្គ្រាង នៅក្នុងបន្ទប់នោះឯង។ ចិត្រ៖ "អាក្រក់អីម្ល៉េះ អ្នកបាទនេះ!" ថៅចិត្រគំរាមខាំធ្មេញ ប្រុងនឹងលោតទៅថែមទៀត តែនាងនារីចាប់ដៃទាន់ ហើយហាមថា "ប៉ុណ្ណឹងបានហើយ ចិត្រ កុំថែមទៀត"។
លោកបាឡាត់ស្ទុះក្រោកឡើង ប្រុងលោតមកសងសឹកវិញ ស្រាប់តែហ្លួងរតនសម្បត្តិនិងថៅកែផាន់ដើរចូលមកក្នុងបន្ទប់នេះ ទើបលោកបាឡាត់នោះទប់ង៉ក់ លោកហ្លួងងាកទៅមើលមុខថៅចិត្រ ហើយបែរមកមើលមុខលោកបាឡាត់ ដោយលោកមានសេចក្ដីងឿងឆ្ងល់ណាស់ ទើបលោកសួរថា "កើតរឿងអី ថៅចិត្រ ទើបមានសូរអឹកធឹកស្ទើរតែនឹងធ្លាយជញ្ជាំងផ្ទះ?"
ថៅចិត្រមិនឆ្លើយ ស្រាប់តែនារីស្ទុះទៅអោបឪពុក ហើយថា "ប៉ា លោកបាឡាត់នោះអាក្រក់ណាស់"។
ហ្លួង៖ "វាម៉េច លោកបាឡាត់ធ្វើអី?" (លោកហ្លួងសួរកូន)
នារី៖ "ចំបាប់ខ្ញុំ គ្រោះល្អបានថៅចិត្រចូលមកទាន់កុំអី!" ថាហើយនាងយំខ្សឹបខ្សួលយ៉ាងឃ្នាន់ខ្នាញ់ក្នុងចិត្តជាទីបំផុត។
លោកហ្លួងទទួលស្ដាប់ពាក្យកូនទើបដើរចូលទៅជិតលោកបាឡាត់នោះ ហើយនិយាយថា "ហេតុអីក៏លោកហ៊ានធ្វើអំពើច្រឡោងខាងដោយឥតអៀនខ្មាស់ដូច្នេះ ខ្ញុំបាទសេពគប់នឹងលោក ដោយជឿទុកចិត្តថាលោកជាមនុស្សល្អជាកល្យាណមិត្តរបស់ខ្ញុំ ឥឡូវលោកបែរជាតបស្នងសងគុណខ្ញុំដោយសកម្មភាពដូច្នេះនេះ ល្មមឈប់សេពគប់រាប់រកគ្នាពីថ្ងៃនេះតទៅ"។

លោកបាឡាត់និយាយសំដីទន់ទៅរកហ្លួងរតនសម្បត្តិថា "ខ្ញុំបាទ បានជាខុសទៅហើយ សូមលោកអត់ទោសអោយម្តងចុះ"។
លោកហ្លួងធ្វើជាសើចសោះកក្រោះហើយថា "លោកបាឡាត់បានដឹងថាខ្លួនខុសនោះ វាហួសវេលាទៅហើយ តែណ្ហើយចុះ ខ្ញុំមិនប្រកាន់ទោសពៃរ៍អ្វីទេ ត្រង់ដែលលោកមកធ្វើល្មើសលើខ្ញុំជាទម្ងន់ក្នុងគ្រានេះ ខ្ញុំអត់ទោសអោយ តែយើងត្រូវលែងស្គាល់រាប់អានគ្នាទៅទៀត ដ្បិតអំពើដែលលោកបានធ្វើនេះវាអាក្រក់អបល័ក្ខណ៍គួរអោម៉ាស់មុខណាស់ តែកាលបើលោកដឹងខ្លួនថាខុស នុះន៎! ទ្វារចេញ សមគួរតែលោកដើរចេញទៅ កុំបីចូលមកវិញទៀតអោយសោះ!"
លោកហ្លួងថាហើយ ក៏បែរចេញទៅរកថៅកែផាន់ហើយប្រាប់ថា "ខ្ញុំនឹកស្តាយណាស់ក្នុងព្រឹត្តិការណ៍ដែលកើតឡើងអម្បាញ់មិញនេះ "។
ថៅកែផាន់មិននិយាយថាដូចម្តេច ដើរសម្តៅទៅរកលោកបាឡាត់ទះស្មាតិចៗ ហើយថា "ទៅលោកបាឡាត់ កុំបីតូចចិត្តទោមនស្សអ្វី! ព្រោះអំពើដែលលោកបានធ្វើមកនេះជាការខុសពិត"
ហើយក៏ដឹកដៃលោកបាឡាត់។ លោកបាឡាត់អោនមុខដើរចេញតាមទ្វារនោះទៅ។ ខាងឯលោកហ្លួងក៏មិនបានប្តឹងផ្តល់ដែលជាការតរឿងរ៉ាវឲ្យវែងឆ្ងាយតទៅទៀត ដោយលោកនឹកថាជាគ្រោះថ្នាក់របស់លោកនិងបុត្រីរបស់លោកទើបស្លេះរឿងនេះទុកត្រឹមប៉ុណ្ណោះ។

វេលាព្រលប់ចូលយប់សន្ធ្យា ព្រះចន្ទ្ររះឡើងពីបូព៌ាទិស យ៉ាងត្រចះត្រចង់ ព្រឹត្តិការណ៍ដែលកើតឡើងពីពេលរសៀលមិនទាន់រលុបបាត់ពីខួរក្បាលរបស់ថៅចិត្រ។ វេលានោះថៅចិត្រកំពុងអង្គុយបណ្តែតចិត្តទៅតាមអារម្មណ៍ដែលគិតនឹក នៅនារបៀងផ្ទះ ចោលភ្នែកក្រឡេកមើលទៅលើមេឃឃើញពពកមួយដុំធំកំពុងអណ្តែតត្រសែតទៅទិសខាងកើត ស្តាប់សំលេងស្លឹកឈើឮសូរប្រាវៗ ដែលត្រូវខ្យល់បក់។ សុនខនៅខាងផ្ទះជិតខាងក៏ព្រុសគឹកកង ហើយស្រែកលូយ៉ាងលន្លង់លន្លោច។
ថៅចិត្រក៏ចាប់ភ្លឹកនឹកដល់ឪពុកដែលអនិច្ចកម្មទៅហាក់ដូចជានៅថ្មីៗ នឹកឡើងវេលាណា ទឹកភ្នែកក៏ហូរសស្រាក់មកដោយមិនដឹងខ្លួនប្រាណ ហើយនឹករលឹកដល់បណ្តាំរបស់ឪពុក មុនដែលបានលះបង់លោកនេះទៅ ថៅចិត្រគិតឃើញថាខ្លួនរបស់ខ្លួនឯងពិតៗ ខំតាំងខ្លួនប្រាណឡើងមកនេះ គិតទៅគិតមកគំនិតថៅចិត្រជាប់នៅទើលើរូបនាងនារីទាំងអស់ នាងនារីតែមួយដែលអាចជួយញ៉ាំងជីវិតរបស់គេឲ្យស្រស់បស់ផូរផង់ទៅមុខ ប្រសិនបើបែរជាមិនសម្រេចដូចបំណាង ជីវិតរបស់ថៅចិត្រស្ទើរតែទៅជាសោះសូន្យឥតរីករាយឡើយ តែគេជឿជាក់ក្នុងសេចក្តីមេត្រីស្នេហារវាងនារីនិងខ្លួនគេជាទីបំផុត នឹកដល់ត្រង់ណោះថៅចិត្រក៏ញញឹមប៉ប្រឹមតែម្នាក់ឯង ហើយគេក្រោកឡើងដើរចូលក្នុងបន្ទប់ ប្រះខ្លួនដេកលើពូកខ្នាតតូចដែលនាងនារីដេរឲ្យដោយដៃរបស់នាង ទម្លាក់មុងទាញភួយមកដណ្តប់ ប្រុងស្មារតីនឹងដេកឲ្យលក់សប្បាយ។

អាកាសនោះវេលាយប់ជ្រៅទៅនៅស្រុកបប៉ៃលិនត្រជាក់ខ្លាំងបន្តិច ផ្ទៃមេឃស្រឡះ ប្រាសចាកពពក

ដួងចន្ទ្រហាក់ដូចជាបណ្តែតនៅលើកំពូលភ្នំប៉ៃលិន បញ្ចាំងពន្លឺសស្អាត សាចចូលតាមចន្លោះបង្អួច មានខ្យល់រំភើយៗ បក់ចូលមកប៉ះនឹងខ្សែមុងរវិចៗ សូរស័ព្ទឆ្កែព្រុសនិងសូរលូនៅតែឮមិនដាច់សំលេង។ ថៅចិត្រដេកសំលឹងមើលដួងចន្ទ្រ ហើយធ្មេចភ្នែកជិតតែនឹងដេកលក់ទៅហើយ។

ប៉ុង! ប៉ុង! សូរកាំភ្លើងលាន់ឡើងនៅក្បែរខាងបរិវេណផ្ទះ ដូចជាដាស់ថៅចិត្រដែលជិតលក់ឲ្យភ្ញាក់ឡើងវិញ ហើយគេបានស្ទុះក្រោកឡើងយ៉ាងប្រញាប់ប្រញាល់ អង្គុយចាំស្តាប់ឲ្យដាក់ច្បាស់ តើមានហេតុអ្វីកើតឡើង? ភ្នែកសំឡឹងមើលកាំភ្លើងដែលព្យួរនៅនឹងជញ្ជាំងខាងក្បាលដំណេក ជារបស់ដែលហ្លួងរតនសម្បត្តិឲ្យទុកបង្ការអន្តរាយ ស្ងប់ស្ងាត់ទៅមួយស្របក់ ប៉ុង! ប៉ុង! ប៉ុង! ប៉ុង! សូរក៏លាន់ឮឡើងទៀតជាច្រើនណាត់។ ថៅចិត្រក៏ស្ទុះក្រោកឡើងចាប់កាំភ្លើងស្ទុះចុះពីផ្ទះមកស្រាប់តែឃើញភ្លើងភ្លឺរន្ទាលអស់ទាំងភូមិ ទើបរត់ទៅផ្ទះពួកកម្មករ ក៏ឃើញពួកកម្មកររួមផ្តុំគ្នា ខ្លះកាន់កាំភ្លើង ខ្លះកាន់លំពែង ខ្លះកាន់ដាវប្រុងខ្លួនជាស្រេច សូរកាំភ្លើងលាន់ឮច្រើនទៀតជាច្រើនណាត់ ព្រមទាំងសូរហ៊ោរបស់ពួកចោរយ៉ាងអឺកធឹក បន្តិចស្រាប់តែឮសូរស្រែកអេះៗនៅលើផ្ទះធំ ថៅចិត្រចាំច្បាស់ថាជាសម្លេងរបស់ហ្លួង។

"អាពួកនេះអាក្រក់ណាស់ វាឃើញផ្ទះណាមានទ្រព្យសម្បត្តិវាតែងនាំបក្សពួកវាចូលប្លន់" នេះជាសំលេងតាសុន អ្នកបររថយន្តឮល្វើយៗមកតាមខ្យល់។

ថៅចិត្រដឹងប្រាកដជាមានពួកចោរចូលប្លន់ ក៏នាំពួកកម្មករចេញទៅសំដៅផ្ទះធំយ៉ាងរួសរាន់ ក៏ស្រាប់តែឃើញពួកចោរជាច្រើន កំពុងប្រវាតោងរបងភូមិ ឡើងចូលមកក្នុងភូមិ សឹងមានអាវុធគ្រប់ដៃ ហើយក៏នាំពួកកម្មករទៅប្រយុទ្ធនឹងពួកចោរយ៉ាងម៉ឺងម៉ាត់។

ការតស៊ូរវាងពួកចោរនិងពួកកម្មករសុទ្ធតែមានអាវុធគ្រប់ដៃទាំងសងខាង កាន់តែខ្លាំងឡើងៗដល់ថ្នាក់ប្រឡូកគ្នាមិនគិតស្តាយជីវិតរៀងខ្លួន។ ឯថៅចិត្រអែបនឹងដើមឈើមួយដើម ជាទីកំបាំងលើកកាំភ្លើងបាញ់តំរង់ចោរម្នាក់ដួលផ្ងារទៅដោយគ្រាប់កាំភ្លើងមួយគ្រាប់ដំបូង ១គ្រាប់ទៀតត្រូវចោរម្នាក់ទៀតកាន់ដាវនៅដៃទាំងពីរដួលទៅទៀត ខណៈនោះសូរស្រែកហ៊ោ សូរកាំភ្លើង សូរថ្ងូររបស់អ្នកដែលត្រូវរបួសក៏លាន់ឮកងរំពងទូទាំងភូមិ។

ថៅចិត្រទុកបណ្តោយឲ្យពួកកម្មករតទល់នឹងពួកចោរនៅខាងក្រោយ ខ្លួនឯងដោះដៃស្ទុះរត់ឡើងទៅលើផ្ទះធំ គេបានឮសូរសំឡេងតស៊ូយ៉ាងអឺកធឹកនៅបន្ទប់ទទួលភ្ញៀវ ក៏ស្ទុះភ្លែតចូលទៅ ស្រាប់តែឃើញចោរមាឌធំខ្មៅគំរឹលម្នាក់ ចាប់ក្រវាត់លោកហ្លួងដួលឮសូរគ្រាំងនៅកណ្តាលល្វែងបន្ទប់នោះឯង។

ថៅចិត្រស្រែកឡើងថា "អាផាន់ អាជាថៅកែចោរឬ? អានាំពួកចោរមកប្លន់ឬ?"

អាផាន់ជាមហាចោរចិត្តទមិឡ ខាំមាត់សំញេញធ្មេញសស្វាចជាយក្សា តបទៅថា "អើអញ! នេះអញត្រលប់មកសងសឹកអាវិញឲ្យទាន់ចិត្តហើយ យកត្បូងទាំងអស់របស់ថៅហ្វាយអាទៅផង"។

ចៅចិត្រខាំធ្មេញក្រឹត ហើយលើកកាំភ្លើងតម្រង់ ហើយនិយាយថា "អានេះមិនយកទេឬ?" ហើយបាញ់ប៉ុងសំដៅដើមទ្រូងមហាចោរមួយណាត់ តែមហាចោរវៃចំណាប់គ្រាប់កាំ ភ្លើងត្រូវតែចុងសក់ធ្លុះជញ្ជាំងទៅ ហើយវាស្ទុះភ្លែតដាល់ខ្លួនចៅចិត្រប៉ះយ៉ាងខ្លាំង ចៅចិត្រភ្លាត់ចំណាប់ដួលផ្ងាចង្ក្រាង កាំភ្លើងរបូតទៅនៅកៀនជញ្ជាំង តែចៅចិត្រក៏វៃចំណាប់ ម្នីម្នាក្រោកឡើងស្ទុះភ្លែតដាក់មហាចោរវិញ មួយដៃដំបូងត្រូវថ្គាមក្បែរគុម្ពត្រចៀក ញ៉ាំងមហាចោរឲ្យទ្រេតថយឃ្លាទៅម្ខាង ចៅចិត្រស្ទុះទៅដាល់មួយដៃថែមទៀត តែបែរជាត្រូវមហាចោរវាត់មួយដៃត្រូវខាងលើត្របកភ្នែកខាងឆ្វេង រាងកាយតូចស្ដើងរបស់ចៅចិត្រក៏វិលខ្វាល់ទៅប៉ះនឹងជញ្ជាំងផ្ទះ មហាចោរស្ទុះមកនឹងថែមយ៉ាងពេញទំហឹងដែរ តែចៅចិត្រគេចផុតទៅបន្តិច ទើបធ្វើឲ្យមួយដៃលើកក្រោយយ៉ាងដំណំរបស់មហាចោរនេះត្រូវជញ្ជាំងផ្ទះឮសូរគ្រាំង ស្ទើរបែកធ្លាយចេញទៅ។ មហាចោររលាស់ដៃជាប្រញាប់ ក៏ស្រាប់តែប៉ះនឹងកណ្ដាប់ដៃរបស់ចៅចិត្រយ៉ាងធ្ងន់ត្រង់បបូរមាត់ចេញឈាមខ្វាយ តែមហាចោរចិត្តមុតគ្រាន់តែទ្រេតទៅបន្តិចក៏ស្ទុះចូលមកដាក់ចៅចិត្រវិញ។ ចៅចិត្រតោងថយក្រោយពីរបីជំហានដោយនឹកស្ញើបនឹងកណ្ដាប់ដៃយក្សរបស់មហាចោរដែលអាចផ្ដួលមនុស្សធម្មតាត្រឹមមួយដៃៗប៉ុណ្ណោះ មហាចោរទាត់ផាំងសំដៅកញ្ចឹងកចៅចិត្រ។ ចៅចិត្រគេចផុតទើបគេតបទៅវិញនឹងកៅអីមួយនៅក្នុងបន្ទប់នោះ មហាចោរលើកដៃកាត់កៅអីបាក់ប្រាវ ហើយមហាចោរស្ទុះចូលមកទៀតដូចជាក្របីព្រៃ ។ ចៅចិត្រថយទៅប៉ះជញ្ជាំងស្រាប់តែជើងទៅជាន់លើកាំភ្លើងទើបប្រញាប់ចាប់កាំភ្លើងឡើងផ្គងលើស្មា ហើយកេះកៃសំដៅដើមទ្រូងមហាចោរដែលស្ទុះក្រទឺក្រទាចូលមកទៀត ប៉ុង! បាត់ផ្សែង រាងកាយសំបើមដូចក្របីព្រៃនៃមហាចោរដួលគ្រេងដេកស្ដូកស្ដឹងនៅក្នុងបន្ទប់នោះឯង។

លុះចៅចិត្រឃើញមហាចោរអស់ឫទ្ធិអំណាចនឹងក្រោកមកស៊ូបានទៀត ទើបងាកទៅពិនិត្យមើលលោកហ្លួងរតនសម្បត្តិ ដែលដេកស្រប៉ាបក្នុងបន្ទប់នោះដែរ លើកក្បាលដាក់លើភ្លៅហើយចាប់អង្រួនលោកហ្លួងក៏បើកភ្នែកឡើងហើយសួរខ្សាវៗយ៉ាងអស់កម្លាំងថា "អាផាន់ ទៅណាហើយ?"

ចិត្រ៖ "ស្លាប់ហើយទានប្រោស ព្រះតេជព្រះគុណល្មមមានកម្លាំងក្រោកអង្គុយបានឬទេ?"

ហ្លួង៖ "ល្មមអង្គុយបាន ខ្លួនខ្ញុំមិនជាអ្វីទេ គ្រាន់តែអស់កម្លាំងណាស់ អាឆ្កួតនោះវាចាប់ឯងបោកស្ទើរប្រកាច់"។ ហ្លួងរតនសម្បត្តិនិយាយមិនទាន់ផុតពាក្យ ស្រាប់តែឮសម្លេងស្រីស្រែកយ៉ាងខ្លាំង។ ហ្លួងរតនសម្បត្តិបើកភ្នែកក្រលោត ចាំច្បាស់ជាសម្លេងនារី បុត្រីរបស់លោកក៏ត្រូវពួកចោរចូលលុកលុយដែរ។ ឯចៅចិត្រខ្លួនឯងអស់កម្លាំងជិតដួលទៅហើយ គ្រាន់តែឮសម្លេងនោះស្រែកឡើង ក៏កើតកម្លាំងម៉ឺងម៉ាត់ដូចគោឡើងកមួយរំពេច ទើបគេស្ទុះលោតឡើងទៅបន្ទប់ថ្នាក់លើ ចូលដល់ដំណេកនារីមួយរំពេច ស្រាប់តែឃើញបុរសកម្លោះកំពុងចំបាប់ប្រវាយប្រតប់នឹងនាងនារី។ ចៅចិត្រស្ទុះភ្លែតចាប់កន្ត្រាក់រាងកាយបុរសនោះចេញបានដោយងាយមកឯរបៀង មិនដូចកាលតស៊ូនឹងមហាចោរនុះឡើយ។

ចៅចិត្រស្រែកគំរាមថា "អាបាឡាត់ អាហ៊ានពុះពារចូលដល់ទីនេះឬ?"

"អាចិត្រ អញនឹងបញ្ជូនវិញ្ញាណអាឯងទៅស្ថាននរកឥឡូវនេះឯង" បាឡាត់ស្រែកគំរាមតបវិញ

ហើយចាប់ហូតកាំបិតស្នៀតលើកចាក់សំដៅដើមទ្រូងថៅចិត្រ ថៅចិត្រគេចផុតខុយទៅ ទើបគេជូនមួយកណ្តាប់ដៃសំដៅចំត្របកភ្នែកបាឡាត់។ បាឡាត់ទុច្ចរិតត្រូវតែមួយដៃ ក៏ដួលស្រប៉ាបនៅទីនោះឯង។ នាងនារីស្រែកភ្លាត់សម្លេង ដោយសេចក្តីភិតភ័យស្រឡាំងកាំង។
ថៅចិត្រស្ទុះទៅបីនាងនារីចូលទៅក្នុងបន្ទប់ ហើយថា "ខ្ញុំនឹងកប្បិលវាអោយស្រេចឥឡូវនេះឯង" ថា ហើយថៅចិត្រត្រលប់ទៅវិញជាប្រញាប់ ឯបាឡាត់នោះខំទប់ទល់អាត្មាក្រោកឡើងងេងងោងដូចកលត្រូវមន្តសណ្តំរបស់ហនុមាន។ ថៅចិត្រស្ទុះភ្លែត ចាប់កអាវបាឡាត់ទុច្ចរិតនោះលើកឡើងស្ទួយហើយគម្រាមថា "នេះសម្រាប់នាងនារី!" ហើយដាក់មួយដៃយ៉ាងធ្ងន់ត្រង់ចង្កាបាឡាត់ទុច្ចរិតនោះ បាឡាត់ក៏ដួលផ្ងារចង្រ្កាងទៅទៀត រួចថៅចិត្រចាប់ក្បាលស្ទួយឡើងទៀត ហើយស្រែកថា "នេះសម្រាប់អញ!" ហើយដាក់មួយដៃចំពង់ក រាងកាយរបស់បាឡាត់ទុច្ចរិតក៏ប្រាសចាកវិញ្ញាណ ព្រមទាំងដាក់មួយជើងយ៉ាងដំណំ រាងអសុភក៏អណ្តែតធ្លាក់ចុះមកដីឮសូរគ្រាំង ជាអវសាននៃជីវិតរបស់បាឡាត់ទុច្ចរិតចិត្តអាក្រក់នោះ។

កាលមហាចោរជាធំទាំងពីរនាក់ស្លាប់ហើយ ឯពួកចោរជាបរិវារក៏បែកខ្ចាត់ខ្ចាយ រត់ចូលព្រៃអស់ទៅ។ ខណៈដែលពួកកម្មករដេញពួកចោររត់ខ្ចាត់ខ្ចាយនោះទៅ ពួកកងក្រវែលក៏មកដល់ ហើយជួយដេញពួកចោរខាងក្រោយកម្មករទៅដែរ តែឥតចាប់បានចោរម្នាក់សោះ វៀរលែងតែពួកដែលត្រូវរបួសជាទម្ងន់ ដេកនៅក្នុងភូមិនោះតែប៉ុណ្ណោះ។
ដល់ព្រឹកឡើង ហ្លួងរតនសម្បត្តិចាត់អោយមេធាវីប្តឹងក្រសួងរាជការតាមច្បាប់ អំពីហេតុចោរកម្មដែលកើតឡើងនៅក្នុងយប់នោះសព្វគ្រប់។

# វគ្គទី៧

## អវសាន

ព្រឹកឡើងហ្លួងរតនសម្បត្តិ បានហៅពួកកម្មករទាំងអស់មកប្រជុំគ្នា ហើយបានជប់លៀងអាហារភោជនដើម្បីសំដែងសេចក្ដីត្រេកអរចំពោះកម្មករ ដែលមានចិត្តស្មោះត្រង់ ជួយការពារយ៉ាងម៉ឺងម៉ាត់លុះត្រាតែមានជ័យជំនះពួកចោរ ហើយលោកអនុញ្ញាតឲ្យពួកកម្មករទាំងអស់ឈប់សំរាកធ្វើការមានកំណត់៣ថ្ងៃ។ ក្រោយពេលដែលពួកកម្មករនាំគ្នាលាលោកហ្លួងទៅសំរាកកាងកាយ ដ្បិតសុទ្ធតែអត់ងងុយនឹងនឿយហត់អស់កម្លាំងទាំងអស់គ្នា។ លោកហ្លួងក៏ទៅសំរាករាងកាយដែរ ហើយលោករំពឹងគិតដល់គុណបំណាច់ផ្សេងៗ និងសេចក្ដីស្មោះត្រង់របស់ចៅចិត្រ ដោយសព្វគ្រប់ទៅ ក៏ឃើញថាគេមានមេត្រីចិត្តស្មោះត្រង់ ស៊ូយកជីវិតខ្លួនមកប្ដូរដើម្បីជួយជីវិតលោកនិងជីវិតបុត្រលោកពីគ្រោះមកហើយ សុទ្ធតែអាសន្នធំៗ។ មួយទៀតលោកជ្រាបថា សេចក្ដីស្និទ្ធស្នាលរវាងបុត្រីលោកនឹងរូបចៅចិត្រនោះសោតទៀត លោកក៏បានដឹងច្បាស់ថាមិនអាចនឹងបំរាស់ពង្រាត់ឲ្យដាច់គ្នាបានទេ លោកហ្លួងគិតមកដល់ត្រឹមនេះ ទើបហៅបុត្រីលោក ឲ្យទៅហៅចៅចិត្រ មកនឹងនិយាយការសំខាន់មួយ។

ចៅចិត្រក៏ដើរចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ ខណៈនោះហ្លួងរតនសម្បត្តិ កំពុងអង្គុយផ្អែកលើកៅអីមួយធំ ចៅចិត្រក៏ដើរចូលទៅដោយសេចក្ដីគោរព ហើយជំរាបថា "ទានប្រោស ខ្ញុំបាទមកហើយ"។ ឯនាងនារីក៏ឈរអែបស្ដាប់នៅខាងមាត់ទ្វារបន្ទប់។

ខណៈនោះ នាយចិត្រភ័យផងអរផង នឹកភ័យក្រែងលោកបានដឹងរឿងរបស់ខ្លួននឹងនាងនារីហើយនឹងបណ្ដេញខ្លួនចេញពីផ្ទះនោះទៅ នឹកអរក្រែងលោកត្រេកអរនឹងការតទល់យ៉ាងម៉ឺងម៉ាត់លុះត្រាតែផ្ដាច់ជីវិតមហាចោរបង់ដល់ទៅពីរនាក់កាលពីយប់មិញនេះ ទើបគេខំប្រឹងកាត់ចិត្ត និយាយសួរទៅលោកវិញទៀតថា "រឿងអ្វីទានប្រោស?"

លោកហ្លួង គ្រហែមតិចៗ ហើយថា "រឿងសេចក្ដីគាប់គួរនឹងគុណបំណាច់អ្នកឯងហ្នឹងណ៎ា"។

ចៅចិត្រឮពាក្យនេះបានធូរចិត្ត ដូចគេលើកភ្នំចេញពីទ្រូង។ លោកហ្លួងនិយាយដោយទឹកសំដីចេញទៅដោយសេចក្ដីមេត្តាករុណាថា "ខ្ញុំត្រូវតែតបគុណអ្នកឯងខ្លះ ឮទេ?"។

ចិត្រ៖ "មិនបាច់ទេ ទានប្រោស ខ្ញុំបាទបានធ្វើការគ្រប់យ៉ាងនេះ មិនបានប្រាថ្នាការតបស្នងអំពីព្រះតេជព្រះគុណសោះឡើយ ក្រៅពីសេចក្ដីមេត្តាករុណា ដូចព្រះតេជព្រះគុណសង្គ្រោះដល់ខ្ញុំបាទដល់សព្វថ្ងៃនេះ ក៏ល្មមគ្រប់គ្រាន់ហើយ"។

ហ្លួង៖ "មិនល្មមទេ ចៅចិត្រ ដ្បិតអ្នកឯងយកជីវិតខ្លួនប្ដូរស្ទើរតែមិនរស់ពីរបីគ្រាមកហើយ!" លោកបង្អង់មួយស្របក់ ហើយលាន់សំដីថា "ណ្ហើយចុះ! ចូរនិយាយតាមត្រង់មកតើឯងត្រូវការអ្វីខ្លះ?"

ចិត្រ៖ "ទានប្រោស! ខ្ញុំឥតត្រូវការអ្វីទេ ខ្ញុំបាទជាកូនឈ្នួលរបស់ព្រះតេជព្រះគុណ អំពើដែលខ្ញុំបាទបានធ្វើទៅទាំងប៉ុន្មានសុទ្ធតែធ្វើដោយសេចក្តីកតញ្ញូកតវេទី ចំពោះព្រះតេជព្រះគុណ ឥតត្រូវការបំណាច់រង្វាន់អ្វីឡើយ"។
លោកហ្លួងលើកដៃហាម "មិនបាច់និយាយវេះវាងឲ្យវែងសេចក្តីទេ ខ្ញុំដឹងថាអ្នកឯងនិយាយមិនត្រង់មែនទែនទេ?"
ចៅចិត្រខំប្រឹងកាត់ចិត្តកាត់ថ្លើម និយាយតបដោយសំលេងដាប់ៗ "ខ្ញុំបាទ ... ខ្ញុំបាទ... សូមជំ... ជំរាប ..."
លោកហ្លួងនិយាយកាត់ឡើងថា "ប៉ុណ្ណឹងចុះ ខ្ញុំដឹងហើយថាអ្នកឯងត្រូវការអ្វី ខ្ញុំអាចទាយចិត្តត្រូវទាំងអស់ ណ្ហើយចុះខ្ញុំឲ្យគ្រប់យ៉ាងតាមត្រូវការ" ដល់ត្រង់ណេះលោកអោនខ្សឹបនឹងត្រចៀកនាយចិត្រ ប្រាប់ថា "នោះហ្ន៎! ដែលអ្នកឯងត្រូវការចង់បានស្មើដោយជីវិត មែនទេ?" លោកលើកដៃចង្អុលទៅមាត់ទ្វារ។
ចៅចិត្រងេងងាងទៅមួយស្របក់ ស្ទើរតែមិនជឿត្រចៀកខ្លួនឯង ថាខ្លួនបានឮអម្បាញ់មិញនេះ កាលបានឮស្មារតី ក៏អោនក្រាបនៅចំពោះមុខលោកហ្លួង ថ្លែងពាក្យអរគុណច្រើនជាអនេកដោយបិតិត្រេកអរដ៏លើសលប់ តែគេមិនអាចឮពាក្យពេចន៍ដែលចៅចិត្រនិយាយថាដូចម្តេចឡើយក្នុងខណៈនោះ។

លុះបានឫក្សពារវេលាល្អតាមឫក្សហោរាសាស្ត្រ ទើបហ្លួងរតនសម្បត្តិចាត់ចែងរៀបមង្គលការអាពាហ៍ពិពាហ៍រវាងនាងក្រមុំនារីបុត្រីលោកជាគូនឹងចៅចិត្រ។ នៅឱកាស នោះលោកបានអញ្ជើញអ្នកមុខអ្នកការទាំងអ្នករាជការ អ្នកជំនួញ ទាំងជាតិខ្មែរ ជាតិភូមា ចិន យួន និង បារាំង សឹងមានចំនួនណែនណាន់តាន់តាប់ ហើយលោកបានចែកមត៌កឲ្យគូស្វាមីភរិយាថ្មី ជាងពាក់កណ្តាលទ្រព្យសម្បត្តិរបស់លោក ក្រៅពីនេះលោកនៅមានក្មួយតូចៗពីរបីនាក់ទៀត សុទ្ធតែកំព្រាឪពុកម្តាយទាំងអស់ដែលលោកត្រូវថែរក្សាទំនុកបំរុងតទៀត ហើយលោកត្រូវចែកមត៌កឲ្យកូនកំព្រាទាំងនោះតាមសមគួរផង។

លុះអំណើះកាលតមក គូស្វាមីភរិយាទាំងពីរនាក់ក៏បាននៅរួបរួមគ្នាជាសុខក្សេមក្សាន្ត ត្រាតែកើតកូនពូនជាចៅតវង្សត្រកូលរៀងទៅហោង។

## * * *ចប់ដោយបរិបូណ៌* * *